# សេចក្ដីកែតម្រូវ

យើងខ្ញុំសូមអភ័យទោសចំពោះកំហុសឆ្គងអចេតនានៃការបកប្រែ និងសូមធ្វើសេចក្ដីកែតម្រូវនូវប្រយោគមួយឃ្លាក្នុងអត្ថបទជាភាសាខ្មែរនៅ**ទំព័រទី៥** ដូចខាងក្រោម៖

## ប្រយោគខុស

[...] "គណៈកម្មការសុរិយោដីជាតិ (NCC)"។[៦] គណៈកម្មការសុរិយោដី ពុំមានអាណត្តិក្នុងការដោះស្រាយវិវាទណាដែលមានមូលហេតុដូចខាងក្រោម៖

## ប្រយោគកែតម្រូវ

[...] "គណៈកម្មការសុរិយោដីជាតិ (NCC)"។[៦] ក្នុងករណីដែលមិនអាចឈានទៅដល់ដំណោះស្រាយប្រកបដោយតម្លាភាព ចំពោះករណីវិវាទដីធ្លីដូចមានបង្ហាញខាងក្រោម គណៈកម្មាការសុរិយោដីស្រុក/ខណ្ឌត្រូវបញ្ជូនពាក្យបណ្ដឹងទៅកាន់គណៈកម្មការសុរិយោដីខេត្ត/ក្រុង។

វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា
The NGO Forum on Cambodia
ធ្វើការរួមគ្នាដើម្បីភាពប្រសើរឡើង
Working Together for Positive Change

# ការវិភាគស្ថិតិស្តីពីវិវាទដីធ្លីនៅកម្ពុជា ឆ្នាំ ២០១៣




ភ្នំពេញ, កម្ពុជា
ខែ កញ្ញា ឆ្នាំ ២០១៤
ការបោះពុម្ពជាភាសាខ្មែរ និងអង់គ្លេស

# ការវិភាគស្ថិតិស្តីពីវិវាទដីធ្លីនៅកម្ពុជាឆ្នាំ ២០១៣

កាលបរិច្ឆេទបោះពុម្ពផ្សាយ៖ ខែ កញ្ញា ឆ្នាំ ២០១៤

បោះពុម្ពផ្សាយដោយ៖ វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា

អ្នកសរសេរដោយ៖ មជ្ឈមណ្ឌលស្រាវជ្រាវ និងព័ត៌មាន

វិភាគទិន្នន័យដោយ៖ លោកស្រី នេត ចណ្ណា  មន្ត្រីគ្រប់គ្រងព័ត៌មានភូមិសាស្ត្រ និងទិន្នន័យ

រចនាអត្ថបទដោយ៖ លោក ភួន យូ  មន្ត្រីព័ត៌មាន និងការបោះពុម្ពផ្សាយ

អាសយដ្ឋាន៖ លេខ ៩-១១ ផ្លូវ ៤៧៦ សង្កាត់ទួលទំពូង ១ ខណ្ឌចំការមន

រាជធានីភ្នំពេញ កម្ពុជា ប្រអប់សំបុត្រ៖ ២២៩៥, រាជធានីភ្នំពេញ-៣

ទូរស័ព្ទ៖ (៨៥៥-២៣) ២១៤ ៤២៩

ទូរសារ៖ (៨៥៥-២៣) ៩៩៤ ០៦៣

អ៊ីម៉ែល៖ ngoforum@ngoforum.org.kh

គេហទំព័រ៖ www.ngoforum.org.kh

© វេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា, ខែ កញ្ញា ឆ្នាំ ២០១៤

# សេចក្តីថ្លែងអំណរគុណ

វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា សូមថ្លែងអំណរគុណដល់បុគ្គល និងអង្គការទាំងអស់ដែលបានជួយក្រុមមជ្ឈមណ្ឌលស្រាវជ្រាវ និងព័ត៌មាន (RIC) នៃវេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា ក្នុងការប្រមូលទិន្នន័យដែលបានបង្ហាញជូនក្នុងរបាយការណ៍នេះ។ យើងខ្ញុំសូមអរគុណជាពិសេសចំពោះអង្គការមិនមែនរដ្ឋាភិបាលទាំងអស់ ដែលបានចូលរួមយ៉ាងពេញលេញក្នុងកិច្ចដំណើរការប្រមូលទិន្នន័យ ពោលគឺសមាគមការពារសិទ្ធិមនុស្ស និងអភិវឌ្ឍន៍នៅកម្ពុជា (ADHOC) សម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស (LICADHO) អង្គការឃ្លាំមើលសិទ្ធិមនុស្សកម្ពុជា (Vigilance) សមាគមសិទ្ធិមនុស្សដើម្បីអភិវឌ្ឍន៍ខ្មែរកម្ពុជាក្រោម (KKKHRDA) មជ្ឈមណ្ឌលអប់រំច្បាប់សម្រាប់សហគមន៍ (CLEC) អង្គការអនុផលព្រៃឈើ (NTFP) សមាគមថែរក្សាបរិស្ថាន និងវប្បធម៌ (CEPA) និងសមាជិកបណ្តាញសិទ្ធិដីធ្លី និងសិទ្ធិលំនៅឋាន (LAHRiN) ក៏ដូចជាអាជ្ញាធររាជរដ្ឋាភិបាលថ្នាក់ខេត្តទាំងអស់ ដែលបានផ្តល់ជំនួយក្នុងអំឡុងពេលប្រមូល និងបញ្ជាក់ទិន្នន័យនៅមូលដ្ឋាន។

មជ្ឈមណ្ឌលស្រាវជ្រាវ និងព័ត៌មាន (RIC) ក៏សូមអរគុណផងដែរចំពោះអង្គការ និងតំណាងសហគមន៍ទាំងឡាយដែលបានផ្តល់ព័ត៌មាន។ របាយការណ៍នេះពិតជាមិនអាចរៀបចំបានឡើយបើគ្មានការគាំទ្រដ៏មានតម្លៃរបស់ពួកគេ។

# មាតិកា


អក្សរកាត់...iii
និយមន័យនៃបច្ចេកសព្ទ...iv

**១. ទស្សនៈរួមអំពីវិវាទដីធ្លី...១**
**២. គោលបំណងនៃរបាយការណ៍...៣**
**៣. យន្តការដោះស្រាយវិវាទ...៤**
**៤. វិធីសាស្ត្រ...៩**
៤.១ លក្ខណៈវិនិច្ឆ័យកំណត់ករណីវិវាទដីធ្លី...៩
៤.២ ការប្រមូលទិន្នន័យ និងការធ្វើបច្ចុប្បន្នភាពទិន្នន័យស្តីពីវិវាទដីធ្លី...៩
៤.៣ ឧបករណ៍ប្រើប្រាស់ក្នុងការវិភាគស្ថិតិ...១១
៤.៤ ចំណុចខ្វះខាតនៃវិធីសាស្ត្រ...១១

**៥. លទ្ធផលនៃការវិភាគ...១១**
៥.១ វិវាទដីធ្លីគិតតាមឆ្នាំ...១២
៥.២ វិវាទដីធ្លី និងទីកន្លែងមានវិវាទ...១៣
៥.២.១ ទីតាំងនៃវិវាទដីធ្លីនៅរាជធានីភ្នំពេញ...១៤
៥.២.២ ទីតាំងនៃវិវាទដីធ្លីនៅខេត្តរតនគិរី...១៤
៥.៣ ករណីវិវាទដីធ្លីដែលត្រូវបានដោះស្រាយតាមឆ្នាំ...១៦
៥.៤ ដំណោះស្រាយករណីវិវាទដីធ្លី...១៨
៥.៤.១ ស្ថាប័នទទួលពាក្យបណ្តឹង...១៨
៥.៤.២ ដំណើរការដោះស្រាយវិវាទ...២០
៥.៥ គ្រួសារដែលរងផលប៉ះពាល់ពីវិវាទដីធ្លី...២២
៥.៦ ប្រភេទដីដែលមានវិវាទ...២៤
៥.៧ មូលហេតុនៃវិវាទដីធ្លី...២៦
៥.៨ វិធីសាស្ត្រដែលប្រើប្រាស់ដើម្បីធ្វើលទ្ធកម្មដី...២៧

**៦. ការកាន់កាប់ដីកំពុងមានវិវាទបច្ចុប្បន្ន...២៨**
**៧. វិវាទដីធ្លីដែលបណ្តាលមកពីសម្បទានដីសេដ្ឋកិច្ច...២៩**
**៨. ការផ្លាស់កន្លែងដោយបង្ខំ...៣១**

**៩.សេចក្តីសន្និដ្ឋាន**......................................................................................................**៣២**
**១០. ឧបសម្ព័ន្ធ**......................................................................................................**៣៤**
ឧបសម្ព័ន្ធ ក៖ ផែនទីគ្រួសារដែលរងផលប៉ះពាល់ពីករណីវិវាទដីធ្លីតាមខេត្ត ក្នុងឆ្នាំ ២០១៣
(សូមមើលផ្នែកភាសាអង់គ្លេស **Annex A** ទំព័រទី ២៤)
ឧបសម្ព័ន្ធ ខ៖ ប្រភេទដីដែលរងផលប៉ះពាល់ដោយវិវាទដីធ្លី តាមខេត្ត ក្នុងឆ្នាំ ២០១៣
(សូមមើលផ្នែកភាសាអង់គ្លេស **Annex B** ទំព័រទី ២៥)
ឧបសម្ព័ន្ធ គ៖ ផែនទីករណីវិវាទដីធ្លី តាមខេត្ត ក្នុងឆ្នាំ ២០១៣
(សូមមើលផ្នែកភាសាអង់គ្លេស **Annex C** ទំព័រទី ២៦)
ឧបសម្ព័ន្ធ ទី ១៖ ករណីវិវាទដីធ្លីថ្មី ចំនួន ២៨ ក្នុងឆ្នាំ ២០១៣
(សូមមើលផ្នែកភាសាអង់គ្លេស **Appendix 1** ទំព័រទី ២៧)
ឧបសម្ព័ន្ធ ទី ២៖ ករណីវិវាទដែលបានដោះស្រាយក្នុងឆ្នាំ ២០១៣
(សូមមើលផ្នែកភាសាអង់គ្លេស **Appendix 2** ទំព័រទី ២៨)
ឧបសម្ព័ន្ធ ទី ៣៖ វិវាទដីធ្លីក្នុងឆ្នាំ ២០១២
(សូមមើលផ្នែកភាសាអង់គ្លេស **Appendix 3** ទំព័រទី ៣២)
ឧបសម្ព័ន្ធ ទី ៤៖ ការផ្លាស់កន្លែងដោយបង្ខំក្នុងឆ្នាំ ២០១៣
(សូមមើលផ្នែកភាសាអង់គ្លេស **Appendix 4** ទំព័រទី ៣៣)

# អក្សរកាត់

| | |
|---|---|
| ADHOC | សមាគមការពារសិទ្ធិមនុស្ស និងអភិវឌ្ឍន៍នៅកម្ពុជា |
| CLEC | មជ្ឈមណ្ឌលអប់រំច្បាប់សម្រាប់សហគមន៍ |
| CNRO | អង្គការស្រាវជ្រាវជាតិកម្ពុជា |
| ELC | សម្បទានដីសេដ្ឋកិច្ច |
| GIS | ប្រព័ន្ធព័ត៌មានភូមិសាស្ត្រ |
| GIZ | សហគ្រាសសហព័ន្ធអាល្លឺម៉ង់សម្រាប់សហប្រតិបត្តិការអន្តរជាតិ (GIZ) GmbH |
| HH | គ្រួសារ |
| KKKHYDA | សមាគមសិទ្ធិមនុស្សដើម្បីអភិវឌ្ឍន៍ខ្មែរកម្ពុជាក្រោម |
| LD | វិវាទដីធ្លី |
| LICADHO | សម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស |
| NALDR | អាជ្ញាធរជាតិដោះស្រាយវិវាទដីធ្លី |
| NGOF | វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា |
| PLK | អង្គការពន្លឺកុមារ |
| RGC | រាជរដ្ឋាភិបាលកម្ពុជា |
| RIC | មជ្ឈមណ្ឌលស្រាវជ្រាវ និងព័ត៌មាន |
| SLR | ការចុះបញ្ជីដីធ្លីជាប្រព័ន្ធ |
| SPSS | កម្មវិធីកញ្ចប់ស្ថិតិសម្រាប់វិទ្យាសាស្ត្រសង្គម |
| Vigilance | អង្គការឃ្លាំមើលសិទ្ធិមនុស្សកម្ពុជា |

# និយមន័យនៃបច្ចេកស័ព្ទ

សម្រាប់គោលបំណងនៃរបាយការណ៍នេះ បច្ចេកស័ព្ទខាងក្រោមត្រូវបានប្រើ។ និយមន័យដែលប្រើនៅទីនេះ មានលក្ខណៈជាក់លាក់ចំពោះរបាយការណ៍នេះ ហើយគេគប្បីប្រយ័ត្នប្រយែងក្នុងការប្រើបច្ចេកស័ព្ទនេះនៅក្នុងស្ថានភាពដទៃ។

| | |
|---|---|
| ការបោះបង់ពាក្យបណ្តឹង៖ | សំដៅលើករណីទាំងឡាយ ដែលបណ្តឹងទាមទារដីត្រូវបានលះបង់ ឬ រំលត់ដោយភាគីដើមបណ្តឹង។ |
| ដីកសិកម្ម៖ | ដីដែលសមស្របសម្រាប់ផលិតកម្មកសិកម្ម រួមទាំងដំណាំ និងបសុសត្វ។ |
| ការផ្លាស់កន្លែងដោយបង្ខំ៖ | ការយកមនុស្សដោយបង្ខំប្រឆាំងនឹងឆន្ទៈរបស់ពួកគេចេញពីដីដែលជាកន្លែងពួកគេរស់នៅ ឬ ដែលជាកន្លែងពួកគេធ្វើសកម្មភាពកសិកម្ម។ |
| វិវាទដីធ្លី៖ | ការខ្វែងគំនិតមួយរវាងភាគីចាប់ពីពីរឡើងពាក់ព័ន្ធនឹងសិទ្ធិកាន់កាប់គ្រប់គ្រង ឬ ប្រើដីជាក់លាក់មួយដុំ។ វិវាទដីធ្លីអាចពាក់ព័ន្ធដីមួយក្បាលឬផ្នែកមួយនៃដីមួយក្បាល និងអាចកើតឡើងផងដែរនៅពេលដែលមានការខ្វែងគំនិតពាក់ព័ន្ធនឹងព្រំរវាងក្បាលដីជាប់គ្នា។ |
| អ្នកកាន់កាប់ដីដើម៖ | សម្រាប់គោលបំណងនៃរបាយការណ៍នេះ "អ្នកកាន់កាប់ដីដើម" សំដៅលើជន ឬជនទាំងឡាយដែលបានប្រើ ឬបានកាន់កាប់ដីមានវិវាទមុនពេលវិវាទចាប់ផ្តើម។ |
| ភាគីទីពីរ៖ | សម្រាប់គោលបំណងនៃរបាយការណ៍នេះ "ភាគីទីពីរ" សំដៅលើជនដែលកំពុងទាមទារយកដីរបស់អ្នកកាន់កាប់ដីដើម។ |
| ករណីស្ងាត់ស្ងៀម៖ | សំដៅលើករណីដែលត្រូវបានដាក់ជូនអាជ្ញាធរពាក់ព័ន្ធ ប៉ុន្តែក្នុងអំឡុងពេលឆ្នាំកន្លងទៅ មិនឃើញមានវឌ្ឍនភាពអ្វីសំខាន់ឆ្ពោះរកដំណោះស្រាយឡើយ។ |

# ១. ទស្សនៈរួមអំពីវិវាទដីធ្លី

វិវាទដីធ្លីនៅកម្ពុជា ត្រូវបានគេមើលឃើញយ៉ាងទូលាយថាជាបញ្ហាប្រឈមមួយនៃបញ្ហាប្រឈមដ៏ចំបងៗសម្រាប់ប្រជាជនកម្ពុជា។ ក្នុងករណីអាក្រក់បំផុត វិវាទដីធ្លីអាចនាំទៅដល់ការបាត់បង់ដីធ្លី និងលទ្ធភាពប្រើប្រាស់ធនធាន ដែលមិនមានសង្គតិភាពជាមួយនឹងការសម្រេចគោលដៅកាត់បន្ថយភាពក្រីក្ររបស់រាជរដ្ឋាភិបាលកម្ពុជា។ លើសពីនេះទៀត វិវាទដីធ្លីក៏ជាបញ្ហាប្រឈមដ៏សំខាន់មួយផងដែរចំពោះកេរ្តិ៍ឈ្មោះប្រទេសកម្ពុជា នៅលើឆាកអន្តរជាតិ។

កំណត់ត្រានៅក្នុងប្រព័ន្ធទិន្នន័យរបស់វេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា បង្ហាញថាករណីវិវាទដីធ្លីខ្លះបានកើតឡើងជាច្រើនឆ្នាំមកហើយ ហើយប្រការនេះបានប៉ះពាល់ដល់ស្ថានភាពរស់នៅ និងជីវភាពរបស់ប្រជាពលរដ្ឋដែលរងផលប៉ះពាល់។ កំណត់ត្រាទាំងនេះបង្ហាញថាមានកត្តាជាច្រើនដែលបណ្តាលឲ្យមានវិវាទដីធ្លី រួមមានគម្រោងអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធនៅតំបន់ទីប្រជុំជន និងជនបទ សម្បទានដីសេដ្ឋកិច្ច (ELC) សម្បទានផ្សេងទៀតដែលប្រតិបត្តិការដោយក្រុមហ៊ុនជាតិនិងអន្តរជាតិ និងការរំលោភយកដីដោយអ្នកដទៃផ្សេងទៀត។

តាមច្បាប់តម្រូវឲ្យមានការវាយតម្លៃផលប៉ះពាល់សង្គម និងបរិស្ថាន (SEIA) សម្រាប់គម្រោងនៃការផ្តល់សម្បទានដីសេដ្ឋកិច្ច។ ជាញឹកញាប់ពួកគេមិនបានធ្វើការវាយតម្លៃផលប៉ះពាល់សង្គម និងបរិស្ថានទេ ឬនៅពេលដែលពួកគេធ្វើនោះមិនបានគោរពលក្ខណៈស្តង់ដានោះទេ ហើយផ្តល់ឱកាសតិចតួចសម្រាប់ការចូលរួមជាសាធារណៈ។ កង្វះខាតការវាយតម្លៃហេតុប៉ះពាល់សង្គម និងបរិស្ថាន (SEIA) ដូចដែលត្រូវបានកំណត់ដោយច្បាប់ និងការបរាជ័យក្នុងការអនុវត្តច្បាប់ដើម្បីការពារសិទ្ធិរបស់សហគមន៍មូលដ្ឋាន ក៏ជម្រុញថែមទៀតនូវវិវាទដីធ្លី ហើយដែលវាមិនស្របទៅនឹងគោលដៅអភិវឌ្ឍន៍ដែលបានឯកភាព។

ស្ថិតិដំបូងបំផុតអំពីវិវាទដីធ្លីគឺតាំងពីឆ្នាំ ២០០៧ ហើយវិវាទបានកើនឡើងដល់កំពូលក្នុងឆ្នាំ ២០០៨ ទន្ទឹមគ្នានឹងតម្លៃដីនៅកម្ពុជាដែលបានឡើងយ៉ាងខ្លាំង។ នៅឆ្នាំបន្ទាប់ ចំនួនវិវាទដីធ្លីបានធ្លាក់ចុះបន្តិច ប៉ុន្តែ ក្នុងឆ្នាំ ២០១០ ២០១១ និង ២០១២ វិវាទដីធ្លីបានកើនឡើងជាថ្មី។

ក្នុងបណ្តាឆ្នាំថ្មីៗនេះ រាជរដ្ឋាភិបាលកម្ពុជា បានរៀបចំគោលនយោបាយថ្មី និងក្របខ័ណ្ឌគតិយុត្តិមួយចំនួនទាក់ទិននឹងដីនិងធនធានធម្មជាតិ ដែលមានបំណងសំដៅអនុវត្តនីតិវិធីទាក់ទិននឹងការរៀបចំដែនដីនិងរដ្ឋបាលដីធ្លី រួមមានការទប់ស្កាត់ និងការដោះស្រាយវិវាទដីធ្លី។[1] ប៉ុន្តែគេនៅតែមិនច្បាស់ទេថាតើគោលនយោបាយ និងក្របខ័ណ្ឌថ្មីទាំងនេះទទួលបានជោគជ័យកម្រិតណា ហើយវិវាទដីធ្លីនៅកម្ពុជានៅតែត្រូវបានរាយការណ៍យ៉ាងទូលាយទាំងនៅក្នុងសារព័ត៌មានជាតិ និងអន្តរជាតិ។ ទិន្នន័យដែលបង្ហាញនៅក្នុងរបាយការណ៍នេះអាចខុសគ្នាពីទិន្នន័យដែលបានចេញផ្សាយដោយអង្គការដទៃទៀត ដោយសារតែការប្រើប្រាស់វិធីសាស្ត្រផ្សេងៗគ្នា។ របាយការណ៍នេះ ក៏មានបំណងតាមដានមើលនិន្នាការនៃការកើតឡើង និងមូលហេតុនៃវិវាទដីធ្លី និងផ្តល់ឯកសារជាភស្តុតាងសម្រាប់ភាគីពាក់ព័ន្ធដែលព្យាយាមស្វែងយល់បញ្ហាដ៏សំខាន់នេះផងដែរ។

ដូចមានបង្ហាញជូនក្នុងរបាយការណ៍ ករណីវិវាទដីធ្លីខ្លះបានអូសបន្លាយអស់រយៈដ៏យូរ។ ប្រការនេះ មានផលប៉ះពាល់ខ្លាំងលើជីវភាពរបស់សហគមន៍មូលដ្ឋាន។

---

[1] ឧទាហរណ៍ៈ ច្បាប់ភូមិបាលដែលត្រូវបានអនុម័តដោយរដ្ឋសភា នៅថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ២០០១, សេចក្តីប្រកាសរបស់រាជរដ្ឋាភិបាលកម្ពុជាស្តីពីគោលនយោបាយដីធ្លី (ថ្ងៃទី ១ ខែ កក្កដា ឆ្នាំ ២០០៩), ច្បាប់ស្តីពីអស្សាមិករណ៍ ចុះថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ ២០១០, សារាចរលេខ ០៣ ស្តីពីការដោះស្រាយសំណង់បណ្តោះអាសន្ន ចុះថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០១០, គោលនយោបាយជាតិស្តីពីការអភិវឌ្ឍជនជាតិដើមភាគតិច ឆ្នាំ ២០០៩, អនុក្រឹត្យលេខ ៨៣ (រាជរដ្ឋាភិបាលកម្ពុជា) ចុះថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០០៩ ស្តីពីនីតិវិធីសម្រាប់ការចុះបញ្ជីដីរបស់សហគមន៍ជនជាតិដើមភាគតិច (L&R/L&P/២០០៩/Khm) (Ogs, ឆ្នាំទី ០៩ លេខ ៤៣ ថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ ២០០៩), និង សារាចរអន្តរក្រសួងស្តីពីវិធានការបណ្តោះអាសន្នការពារដីរបស់ជនជាតិដើមភាគតិច ដែលត្រូវបានស្នើសុំប័ណ្ណកម្មសិទ្ធសមូហភាព នៅពេលរង់ចាំការផ្តល់ប័ណ្ណកម្មសិទ្ធិ យើងតាមនីតិវិធីដែលត្រូវបញ្ចប់នៅថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០១១។

## ២. គោលបំណងនៃរបាយការណ៍

គោលបំណងនៃរបាយការណ៍នេះ គឺសំដៅផ្តល់ឯកសារជាភស្តុតាងអំពីវិវាទដីធ្លីដែលបានកត់ត្រាក្នុងឆ្នាំ ២០១៣។ ភស្តុតាងនេះ ត្រូវបានប្រមូលពីអត្ថបទស្តីពីវិវាទដីធ្លីពីសារព័ត៌មានដែលបានបោះផ្សាយ កិច្ចប្រជុំជាមួយសមាជិកបណ្តាញសិទ្ធិដីធ្លីនិងលំនៅឋាន (LAHRiN)[២] និងតាមរយៈការចុះប្រមូលទិន្នន័យផ្ទាល់។ របាយការណ៍នេះ សំដៅបង្កើនការយល់ដឹង និងស្វែងយល់អំពីស្ថានភាពបច្ចុប្បន្នទាក់ទិននឹងវិវាទដីធ្លី និងបំពេញមុខងារជាធនធានមួយសម្រាប់ភាគីពាក់ព័ន្ធផ្សេងទៀតដែលធ្វើការលើបញ្ហាដីធ្លី រួមមានជាអាទិ៍ រាជរដ្ឋាភិបាល និងមន្ត្រីរាជការ ម្ចាស់ជំនួយ សមាជិកបណ្តាញ LAHRiN សង្គមស៊ីវិលកម្ពុជា និងអន្តរជាតិ និងអ្នកសិក្សាស្រាវជ្រាវ។ របាយការណ៍នេះ ក៏នឹងផ្តល់ផងដែរនូវកម្រងឯកសារដែលវេទិកានៃអង្គការមិនមែនរដ្ឋាភិបាល និងក្រុមផ្សេងទៀត អាចប្រើដើម្បីធ្វើការងារតស៊ូមតិដើម្បីលើកស្ទួយសុវត្ថិភាពនៃការកាន់កាប់ដីធ្លីសម្រាប់ប្រជាជនក្រីក្រ និងងាយរងគ្រោះនៅកម្ពុជា។

លើសពីនេះ សង្ឃឹមថាខ្លឹមសារនៃរបាយការណ៍នេះនឹងមានប្រយោជន៍ចំពោះស្ថាប័នពាក់ព័ន្ធរាជរដ្ឋាភិបាលដែលកំពុងធ្វើការ ដើម្បីស្វែងរកដំណោះស្រាយចំពោះស្ថានភាពដីធ្លីបច្ចុប្បន្ននៃកម្ពុជា។ ទោះបីជាវេទិកានៃអង្គការមិនមែនរដ្ឋាភិបាលដឹងថាបញ្ហាប្រឈមមានលក្ខណៈពិបាកខ្លាំងក្តី ក៏សង្ឃឹមដែរថាលទ្ធផលនៃការវិភាគវិវាទដីធ្លីនេះនឹងរួមចំណែកដល់ការអនុវត្តគោលនយោបាយ និងសកម្មភាពទាំងឡាយ ដែលនឹងនាំទៅដល់ការដោះស្រាយវិវាទដីធ្លីទាំងនេះ។

---

[២] LAHRiN គឺជាបណ្តាញនៃអង្គការដែលធ្វើការងារលើបញ្ហាសិទ្ធិដីធ្លីនិងលំនៅឋាននៅកម្ពុជា។ បណ្តាញនេះមានបីកម្រិត៖ ១) គណៈកម្មាធិការដឹកនាំ ដែលរួមមាននាយកដនៃអង្គការមិនមែនរដ្ឋាភិបាលជ្រើសរើសចំនួនពីរ, ២) គណៈកម្មាធិការជាតិ LAHRiN ដែលរួមមានអ្នកគ្រប់គ្រងកម្មវិធីឬអ្នកគ្រប់គ្រងគម្រោងនៃអង្គការមិនមែនរដ្ឋាភិបាលជាសមាជិក ដែលមានមូលដ្ឋាននៅរាជធានីភ្នំពេញ, និង ៣) សមាជិក LAHRiN ថ្នាក់ខេត្តដែលរួមមានអង្គការមិនមែនរដ្ឋាភិបាលដែលមានមូលដ្ឋាននៅតាមខេត្ត ដែលធ្វើការលើបញ្ហាសិទ្ធិដីធ្លី និងលំនៅឋាន។

# ៣. យន្តការដោះស្រាយវិវាទ

ក្នុងបរិបទនៃវិវាទដីធ្លី វាគឺជាប្រការសំខាន់ដែលត្រូវបែងចែករវាងវិវាទលើដី "គ្មានប័ណ្ណកម្មសិទ្ធិ" ដែលពុំមានប័ណ្ណកម្មសិទ្ធិដីផ្លូវការត្រូវបានចេញជូន និងវិវាទលើដី "មានប័ណ្ណកម្មសិទ្ធិ"។ មានយន្តការដោះស្រាយវិវាទផ្សេងៗពីគ្នាជាច្រើនសំរាប់ដោះស្រាយវិវាទដីធ្លីដែលវាអាស្រ័យទៅតាមប្រភេទនៃវិវាទដីធ្លី ។

មានយន្តការដោះស្រាយវិវាទផ្លូវការចំនួនប្រាំនៅកម្ពុជា។ យន្តការទាំងនេះ រួមមាន៖

- ក្រុមប្រឹក្សាឃុំ
- គណៈកម្មការសុរិយោដី
- គណៈកម្មការរដ្ឋបាល
- អាជ្ញាធរជាតិដោះស្រាយវិវាទដីធ្លី
- តុលាការ

**ក្រុមប្រឹក្សាឃុំ** មានអាណត្តិ "ផ្សះផ្សារនូវគំនិតដែលផ្ទុយ" ក្នុងចំណោមប្រជាពលរដ្ឋក្នុងឃុំ ប៉ុន្តែមិនមានអំណាចធ្វើសេចក្តីសម្រេចណាមួយទេ។[៣] ទោះបីជាមិនមាននីតិវិធីផ្លូវការសម្រាប់ក្រុមប្រឹក្សាឃុំក្តី ក៏ករណីភាគច្រើនត្រូវបានដាក់ជូនក្រុមប្រឹក្សាឃុំ មុនពេលបញ្ជូនទៅកម្រិតខ្ពស់ជាងនេះ។[៤]

**គណៈកម្មការសុរិយោដី** មានយុត្តាធិការនៅក្នុងវិវាទលើដីគ្មានប័ណ្ណកម្មសិទ្ធិ។[៥] គណៈកម្មការសុរិយោដីមាននៅកម្រិតថ្នាក់ស្រុក/ខណ្ឌ "គណៈកម្មការសុរិយោដីស្រុក/ខណ្ឌ (DKCC)" នៅកម្រិតខេត្ត/ក្រុង "គណៈកម្មការសុរិយោដីខេត្ត/ក្រុង (PMCC)" និងនៅកម្រិតថ្នាក់ជាតិ

[៣] មាត្រា ៦ អនុក្រឹត្យលេខ ៤៧ អនក.បក ចុះថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០០២ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈកម្មការសុរិយោដី។

[៤] យន្តការដោះស្រាយវិវាទកម្ពុជា, កម្មវិធីសិទ្ធិដីធ្លីនៃអង្គការ GIZ ដំណាក់កាលទី ២ ខែ សីហា ឆ្នាំ ២០១៤, បទបង្ហាញក្នុងកិច្ចប្រជុំដៃគូអភិវឌ្ឍន៍នៃក្រុមការងារបច្ចេកទេសដីធ្លី ខែ សីហា ឆ្នាំ ២០១៤។

[៥] អនុក្រឹត្យលេខ ៤៧ អនក.បក ចុះថ្ងៃទី ខែ ឧសភា ឆ្នាំ ២០០២។

"គណៈកម្មការសុរិយោដីជាតិ (NCC)"។[៦] គណៈកម្មការសុរិយោដី ពុំមានអាណត្តិក្នុងការដោះស្រាយវិវាទណាដែលមានមូលហេតុខាងក្រោម៖

(១) បុគ្គលម្នាក់ទាមទារដីច្រើនក្បាលដែលត្រូវបានទាមទារដោយអ្នកកាន់កាប់ដីតូចតាចផ្សេងទៀតផងដែរ។

(២) ភាគីមួយនៃភាគីវិវាទគឺជាអាជ្ញាធរមានឋានៈខ្ពស់។

(៣) មានវិវាទផលប្រយោជន៍ជាមួយប្រធានគណៈកម្មការសុរិយោដីស្រុក/ខណ្ឌ។

(៤) វិវាទពាក់ព័ន្ធដីសាធារណៈរបស់រដ្ឋ។[៧]

ជាទូទៅ វិវាទនីមួយៗនឹងត្រូវឆ្លងកាត់នីតិវិធីខាងក្រោមៈ ការដាក់ពាក្យបណ្តឹង ការស៊ើបអង្កេត កិច្ចប្រជុំរដ្ឋបាល ការផ្សះផ្សារគ្នា និងការចុះបញ្ជី។[៨] គណៈកម្មការសុរិយោដីថ្នាក់ស្រុក/ខណ្ឌជាកម្រិតដែលទាបជាងគេ មិនមានអំណាចសម្រេចចិត្តលើវិវាទណាមួយឡើយ។ សិទ្ធិអំណាចនៃការសម្រេចចិត្តលើវិវាទជាសមត្ថកិច្ចរបស់គណៈកម្មការសុរិយោដីថ្នាក់ខេត្ត / ក្រុង (PMCC) និងគណៈកម្មការសុរិយោដីថ្នាក់ជាតិ ក្រោយពីមានការព្យាយាមផ្សះផ្សារបីដងរួចមក។[៩] ក្នុងអំឡុងពេលពីរបីឆ្នាំកន្លងមកនេះ គណៈកម្មការសុរិយោដីទទួលជោគជ័យកាន់តែច្រើនក្នុងការដោះស្រាយវិវាទ។ ក្នុងឆ្នាំ ២០០៦ មានតែ ៥១% នៃករណីប៉ុណ្ណោះដែលត្រូវបានចាត់ការយ៉ាងពេញលេញ ហើយ ៤៩% ទៀតនៅមិនទាន់បានដោះស្រាយនៅឡើយ។ ក្នុងឆ្នាំ ២០១១ ៧៨% នៃករណីដែលបានទទួលដោយគណៈកម្មការសុរិយោដី ត្រូវបានដោះ

[៦] មាត្រា ១០ អនុក្រឹត្យលេខ ៤៧ អនក.បក ចុះថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០០២ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈកម្មការសុរិយោដី។

[៧] ឯកសារដដែល សូមមើលកម្មវិធីសិទ្ធិដីធ្លីនៃអង្គការ GIZ ដំណាក់កាលទី ២ ខែ សីហា ឆ្នាំ ២០១៤, បទបង្ហាញក្នុងកិច្ចប្រជុំដៃគូអភិវឌ្ឍន៍នៃក្រុមការងារបច្ចេកទេសដីធ្លី ខែ សីហា ឆ្នាំ ២០១៤ ផង។

[៨] ប្រកាសលេខ ១១២ ដណស/ប្រក ចុះថ្ងៃទី ២១ ខែ សីហា ឆ្នាំ ២០០២ ស្តីពីគោលការណ៍ណែនាំ និង នីតិវិធីនៃ គណៈកម្មការសុរិយោដី, សូមមើលកម្មវិធីសិទ្ធិដីធ្លីនៃអង្គការ GIZ ដំណាក់កាលទី ២ ខែ សីហា ឆ្នាំ ២០១៤, បទបង្ហាញក្នុងកិច្ចប្រជុំដៃគូអភិវឌ្ឍន៍នៃក្រុមការងារបច្ចេកទេសដីធ្លី ខែ សីហា ឆ្នាំ ២០១៤ ផង។

[៩] មាត្រា ២៩ ប្រកាសលេខ ១១២ ដណស/ប្រក ចុះថ្ងៃទី ២១ ខែ សីហា ឆ្នាំ ២០០២ ស្តីពីគោលការណ៍ណែនាំ និង នីតិវិធីនៃ គណៈកម្មការសុរិយោដី, សូមមើលកម្មវិធីសិទ្ធិដីធ្លីនៃអង្គការ GIZ ដំណាក់កាលទី ២ ខែ សីហា ឆ្នាំ ២០១៤, បទបង្ហាញក្នុងកិច្ចប្រជុំដៃគូអភិវឌ្ឍន៍នៃក្រុមការងារបច្ចេកទេសដីធ្លី ខែ សីហា ឆ្នាំ ២០១៤ ផង។

ស្រាយបដិសេធ ឬ ដកចេញវិញដោយដើមបណ្តឹង និងមានតែ ២២% ប៉ុណ្ណោះដែលនៅមិនទាន់បានដោះស្រាយ។[១០] ចាប់តាំងពីខែ មេសា ឆ្នាំ ២០០៣ រហូតដល់ចុងខែ មេសា ២០១៤ គណៈកម្មការសុរិយោដីគ្រប់កំរិត បានទទួលបណ្តឹង ៦,២២៤ ករណី ហើយបានចាត់ការ ៥.៣៧០ ករណី។ ៨៥៤ ករណីនៅមិនទាន់បាន ដោះស្រាយ ។ ក្នុងចំណោមករណីដែលបានចាត់ការ មាន ២.៧៤២ ករណី ជោគជ័យក្នុងការផ្សះផ្សារ ដែលចំនួនករណីនេះ ស្មើរនឹង ១៣.១៩២ គ្រួសារ និង ៣.៨៩៥ ហិកតា។ ករណី ចំនួន ២.០១១ ករណី បានប្រានចោល និង ៦១៧ ករណី បានដកចេញ ។ ចំនួនករណីវិវាទដីធ្លីដែលប្តឹងទៅគណៈកម្មការសុរិយោដីមានការធ្លាក់ចុះចាប់ពិ ឆ្នាំ ២០០៧ រហូតដល់ ចុងខែ សីហា ឆ្នាំ ២០១៣។ ការធ្លាក់ចុះនេះនៅតែបន្តក្រោយពីការបង្កើតក្រុមការងារចល័តដែលគាំទ្រដោយ GIZ។[១១]

**គណៈកម្មការរដ្ឋបាល** មិនមែនជាយន្តការដោះស្រាយវិវាទអចិន្ត្រៃយ៍មួយទេ។ អត្ថិភាពនៃគណៈកម្មការរដ្ឋបាលនេះ គឺមានលក្ខណៈបណ្តោះអាសន្នតែប៉ុណ្ណោះ ក្នុងអំឡុងពេលចុះបញ្ជីដីធ្លីជាប្រព័ន្ធ។ ចំនួននៃគណៈកម្មការរដ្ឋបាលស្មើរគ្នាទៅនឹងចំនួនឃុំដែលបានអនុវត្តការចុះបញ្ជីដីធ្លីជាប្រព័ន្ធ។[១២] គណៈកម្មការរដ្ឋបាលមានភារកិច្ចផ្សះផ្សារវិវាទលើក្បាលដីមិនមានប័ណ្ណកម្មសិទ្ធិ ទោះបីជាត្រូវបានទាមទារដោយបុគ្គល ក្រុមហ៊ុន ឬ រដ្ឋក្តី។ ករណីផ្សះផ្សារមិន

---

[១០] <u>លទ្ធភាពទទួលបានប័ណ្ណកម្មសិទ្ធិដីធ្លីនៅកម្ពុជា ការសិក្សាមួយស្តីពីការចុះបញ្ជីដីក្នុងលក្ខណៈជាប្រព័ន្ធនៅក្នុងខេត្តចំនួនបី និង រាជធានី នៃប្រទេសកម្ពុជា,</u> M. Grimsditch, K. Leakhana, D. Sherchan, បោះពុម្ពផ្សាយដោយវេទិកានៃអង្គការមិនមែនរដ្ឋាភិបាល រាជធានីភ្នំពេញ ខែ កញ្ញា ឆ្នាំ ២០១២ ទំព័ ៨៦, ៨៧។

[១១] យោងតាមព័ត៌មានដែលផ្តល់ដោយកម្មវិធីសិទ្ធិដីធ្លីអង្គការ GIZ ពីអំឡុងខែមិថុនាឆ្នាំ ២០១៣ ដល់ខែមេសា ឆ្នាំ ២០១៤ មាន ៤៨០ ករណីបានដំណើរការ ដែលក្នុងនោះ២៩៥ ករណីត្រូវបានដោះស្រាយ ១៣៣ ករណីបានបញ្ជូនទៅតុលាការ ឬមិនចាត់ការ និង ៥២ករណីបានដកចេញ។ ក្រុមការងារចល័តបានដោះស្រាយ ២៦៩ករណី នៃវិវាទខាងលើនេះ ក្នុងនោះមាន ៣៥ ករណី មានភាគីច្រើនពាក់ព័ន្ធ ដែលមានភាគីចាប់ពី ២ ទៅដល់ ១០ ភាគី ហើយ ២២ ករណីទៀត មានភាគីពាក់ព័ន្ធចាប់ពី ១០ ភាគី។ ជាសរុប មាន ៧៧ ករណីដែលមានភាគីពាក់ព័ន្ធច្រើន បានដោះស្រាយក្នុងរយៈពេល ១១ ខែ។

[១២] យន្តការដោះស្រាយវិវាទកម្ពុជា, កម្មវិធីសិទ្ធិដីធ្លីនៃអង្គការ GIZ ដំណាក់កាលទី ២ ខែ សីហា ឆ្នាំ ២០១៤, បទបង្ហាញក្នុងកិច្ចប្រជុំដៃគូអភិវឌ្ឍន៍នៃក្រុមការងារបច្ចេកទេសដីធ្លី ខែ សីហា ឆ្នាំ ២០១៤។

បានជោគជ័យ ត្រូវបញ្ជូនទៅឲ្យគណៈកម្មការសុរិយោដីជាតិ។[១៣] ក្នុងកំឡុងពេលនៃការចុះបញ្ជីដីធ្លីជាប្រព័ន្ធ គណៈកម្មការរដ្ឋបាលដោះស្រាយវិវាទដីដែលមានភាគីពាក់ព័ន្ធឯកជនចាប់ពី ពីរ ឬច្រើនជាងពីរ។ ករណីវិវាទនេះគឺជាញឹកញាប់ច្រើនតែជាបញ្ហាព្រំប្រទល់ក្បាលដី ។ ករណីវិវាទប្រហែល ១២.០០០ ករណីដែលគណៈកម្មការរដ្ឋបាល និងដៃគូរអភិវឌ្ឍន៍ដែលធ្វើការជាមួយ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវដោះស្រាយ ។[១៤] វិវាទព្រំប្រទល់ដែលជាប់ពាក់ព័ន្ធជាមួយដីរដ្ឋ និងដីឯកជនរបស់រដ្ឋមិនធ្វើការកត់ត្រា និងដក់ចេញពីការចុះបញ្ជីជាប្រព័ន្ធ។ ករណីវិវាទចំនួន ០.៣ % នៃបណ្ណ័ដែលបានចែកជូន។ បណ្ណ័កម្មសិទ្ធិប្រមាណជា ៥០០.០០០បណ្ណ័ បានចែកជូនជារៀងរាល់ឆ្នាំ ទោះបីជាយ៉ាងណាក៏ដោយ ក្បាលដីចំនួន ១.៥០០ ក្បាលដី មិនអាចចុះបញ្ជីបាន ដោយសារការគ្រប់គ្រងដីសាធារណៈរបស់រដ្ឋ និងដីឯជនរបស់រដ្ឋមានជម្លោះ។[១៥]

**អាជ្ញាធរជាតិដោះស្រាយវិវាទដីធ្លី** (NALDR) មានយុត្តាធិការលើករណីទាំងឡាយដែល "ស្ថិតនៅក្រៅយុត្តាធិការ" នៃគណៈកម្មការសុរិយោដី ឬតុលាការ។[១៦] ការបែងចែកសមត្ថកិច្ចមិនច្បាស់លាស់នេះ មានលក្ខណៈគួរឲ្យឆ្ងល់ ដោយសារពុំមានករណីណានៅក្រៅសមត្ថកិច្ចរបស់គណៈកម្មការសុរិយោដី ឬ តុលាការទេ។ ជាក់ស្តែង ករណីធំៗស្ទើរតែទាំងអស់ត្រូវបានបញ្ជូនទៅឲ្យអាជ្ញាធរជាតិដោះស្រាយវិវាទដីធ្លី (NALDR) ដែលស្ថិតក្រោមការដឹកនាំរបស់ឧបនាយករដ្ឋមន្ត្រី ហើយមានក្រសួង និងអាជ្ញាធរចំនួន ២៦ ជាសមាជិក។ សមាជិក ១០ រូបផ្សេងទៀត បំពេញមុខងារជាអគ្គលេខាធិការដ្ឋាន ដែលដឹកនាំដោយគណៈរដ្ឋមន្ត្រី និងរដ្ឋលេខាធិការ។ ក្នុងចំណោម ១.៤២១ ករណី ដែលបានទទួលពីឆ្នាំ ២០០៦ ដល់ឆ្នាំ ២០១០ អាជ្ញាធរជាតិដោះស្រាយវិវាទដីធ្លី (NALDR) បានដោះស្រាយតែ ១៥,៨៣% (២២៥) ករណី

[១៣] មាត្រា ៣, ១២ អនុក្រឹត្យលេខ ៤៦ អនក.បក ចុះថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០០២ ស្តីពីនីតិវិធីបង្កើតផែនទីសន្ទស្សន៍សុរិយោដី និង បញ្ជីដី។ សូមមើលយន្តការដោះស្រាយវិវាទកម្ពុជា, កម្មវិធីសិទ្ធិដីធ្លីនៃអង្គការ GIZ ដំណាក់កាលទី ២ ខែ សីហា ឆ្នាំ ២០១៤, បទបង្ហាញក្នុងកិច្ចប្រជុំដៃគូអភិវឌ្ឍន៍នៃក្រុមការងារបច្ចេកទេសដីធ្លី ខែ សីហា ឆ្នាំ ២០១៤ ផង។

[១៤] ព័ត៌មានដែលផ្តល់ដោយ GIZ កម្មវិធីសិទ្ធិដីធ្លី។

[១៥] ឯកសារដដែល យោងតាមលេខយោងទី១៤។

[១៦] មាត្រា ៣ ព្រះរាជក្រឹត្យ នស/រកត/០២០៦/៦៩៧។

ប៉ុណ្ណោះ និងបានបញ្ជូន ៧៣,៣៩% (១០៤៣) ករណីទៅឲ្យអាជ្ញាធរមានសមត្ថកិច្ចផ្សេងទៀត ខណៈដែល ១០,៧៦% ឬ ១៥៣ ករណីនៅមិនទាន់បានចាត់ការនៅឡើយ។[១៧]

**តុលាការ** មានអាណត្តិដោះស្រាយវិវាទលើដីមានប័ណ្ណកម្មសិទ្ធិ។ យុត្តាធិការបឹកម្រិតនៃការដោះស្រាយតាមប្រព័ន្ធតុលាការ ពោលគឺតុលាការដំបូង តុលាការឧទ្ធរណ៍ និងតុលាការកំពូល។ ប៉ុន្តែ ក្នុងការអនុវត្តជាក់ស្តែងប្រជាពលរដ្ឋក្រីក្រពុំមានលទ្ធភាពប្រើប្រាស់ប្រព័ន្ធតុលាការក្នុងការដោះស្រាយវិវាទទេដោយសារថ្លៃសេវាខ្ពស់ពេក។

តារាងខាងក្រោម បង្ហាញឋានានុក្រមនៃយន្តការដោះស្រាយវិវាទដីធ្លី៖




*ប្រភព៖ យន្តការដោះស្រាយវិវាទកម្ពុជា, កម្មវិធីសិទ្ធិដីធ្លីនៃអង្គការ GIZ ដំណាក់កាលទី ២ ខែ សីហា ឆ្នាំ ២០១៤, បទបង្ហាញក្នុងកិច្ចប្រជុំដៃគូអភិវឌ្ឍន៍នៃក្រុមការងារបច្ចេកទេសដីធ្លី ខែ សីហា ឆ្នាំ ២០១៤។*

តារាងខាងក្រោម (សូមមើល ៤.៥.១) បង្ហាញថា ពាក្យបណ្តឹងបានដាក់ជូនអាជ្ញាធរមានចំនួនច្រើន បើទោះបីតាមទ្រឹស្តី កំណត់ថាអាជ្ញាធរមិនមានយុត្តាធិការដោះស្រាយវិវាទដីធ្លីក៏ដោយ។ ករណីជាច្រើន បណ្តឹងបានដាក់ជូនអាជ្ញាធរផ្សេងៗគ្នាក្នុងពេលតែមួយ។

[១៧] យន្តការដោះស្រាយវិវាទកម្ពុជា, កម្មវិធីសិទ្ធិដីធ្លីនៃអង្គការ GIZ ដំណាក់កាលទី ២ ខែ សីហា ឆ្នាំ ២០១៤, បទបង្ហាញក្នុងកិច្ចប្រជុំដៃគូអភិវឌ្ឍន៍នៃក្រុមការងារបច្ចេកទេសដីធ្លី ខែ សីហា ឆ្នាំ ២០១៤ ផង។

# ៤. វិធីសាស្ត្រ

## ៤.១. លក្ខណៈវិនិច្ឆ័យកំណត់ករណីវិវាទដីធ្លី

របាយការណ៍នេះ វិភាគជម្លោះដីដែលបានរាយការណ៍នៅក្នុងប្រព័ន្ធផ្សព្វផ្សាយក្នុងស្រុក និងព័ត៌មានប្រមូលពីសមាជិកបណ្តាញ។ ជម្លោះដីធ្លីដែលបានកើតឡើង ប៉ុន្តែមិនបានរាយការណ៍ដោយប្រព័ន្ធផ្សព្វផ្សាយក្នុងស្រុក និងជម្លោះដីដែលសមាជិកបណ្តាញមិនបានដឹង គឺមិនត្រូវបានដាក់បញ្ចូលទៅក្នុងការវិភាគទេ។ វិវាទដីធ្លីដែលបានរៀបរាប់នៅក្នុងប្រព័ន្ធផ្សព្វផ្សាយក្នុងស្រុកអាចជាវិវាទដី ដែលមានប័ណ្ណកម្មសិទ្ធិ និងវិវាទដីដែលមិនមានប័ណ្ណកម្មសិទ្ធិ។ ស្ថិតិដែលមានក្នុងរបាយការណ៍នេះ អាចខុសពីប្រភពផ្សេងទៀត ដោយសារភាពខុសគ្នាក្នុងវិធីសាស្ត្រ និងលក្ខណៈវិនិច្ឆ័យសម្រាប់ការប្រមូល និងការបញ្ជាក់ទិន្នន័យ។ មជ្ឈមណ្ឌលស្រាវជ្រាវ និងព័ត៌មាន (RIC) ប្រើលក្ខណៈវិនិច្ឆ័យខាងក្រោមដើម្បីកំណត់ករណីវិវាទដីធ្លី៖

- ករណីវិវាទដីធ្លីពាក់ព័ន្ធចាប់ពី ៥ គ្រួសារឡើង
- ករណីវិវាទដីធ្លីដែលមិនទាន់បានដោះស្រាយ ឬ បានដោះស្រាយខ្លះ និង
- ករណីវិវាទដីធ្លីដែលត្រូវបានបញ្ជាក់ថាបានដោះស្រាយមុន**ឆ្នាំ ២០១៣** មិនត្រូវបានរាប់បញ្ចូលក្នុងការវិភាគនេះទេ។ ប៉ុន្តែ ករណីទាំងឡាយដែលត្រូវបានដោះស្រាយ**ក្នុងអំឡុងឆ្នាំ ២០១៣** ត្រូវបានរាប់បញ្ចូល។

## ៤.២ ការប្រមូលទិន្នន័យ និងការធ្វើបច្ចុប្បន្នភាពទិន្នន័យស្តីពីវិវាទដីធ្លី

ប្រព័ន្ធនៃការប្រមូលទិន្នន័យ និងការធ្វើបច្ចុប្បន្នភាពទិន្នន័យនៃមជ្ឈមណ្ឌលស្រាវជ្រាវ និងព័ត៌មាន (RIC) ដំណើរការដូចខាងក្រោម៖

- ការប្រមូលព័ត៌មានស្តីពីករណីវិវាទដីធ្លីប្រចាំថ្ងៃ ត្រូវបានធ្វើតាមរយៈការតាមដានមើលសារព័ត៌មានក្នុងស្រុក (រួមមាន កាសែតភ្នំពេញប៉ុស្ត៍ វិទ្យុអាស៊ីសេរី កាសែតខែមបូឌៀដេលី កោះសន្តិភាព និងរស្មីកម្ពុជា)។

- ផ្អែកលើព័ត៌មានដែលប្រមូលបាន ករណីនីមួយៗត្រូវឆ្លងកាត់ការផ្ទៀងផ្ទាត់ដើម្បីជៀសវាងការដាក់បញ្ចូលព័ត៌មានត្រួតគ្នានៅក្នុងទិន្នន័យ ជាមួយសមាជិកបណ្តាញ LAHRiN នៅតាមខេត្ត តាមរយៈកិច្ចប្រជុំរាល់ពីរខែម្តង។

- កិច្ចប្រជុំរាល់ពីរខែម្តង ផ្តល់ឱកាសមិនត្រឹមតែសម្រាប់ធ្វើការផ្ទៀងផ្ទាត់ករណីវិវាទដីធ្លីប៉ុណ្ណោះទេ ប៉ុន្តែក៏ដើម្បីប្រមូលព័ត៌មានវិវាទដីធ្លីដែលមិនបានរាយការណ៍នៅក្នុងសារព័ត៌មាន ដែលគេដឹងថាកំពុងកើតឡើងនៅតាមតំបន់គោលដៅរបស់សមាជិកបណ្តាញ។

- សមាជិកបណ្តាញ LAHRiN នៅតាមខេត្ត ធ្វើការផ្ទៀងផ្ទាត់វិវាទដីធ្លីជាក់ស្តែងនៅមូលដ្ឋាន។ ដើម្បីប្រមូលទិន្នន័យពាក់ព័ន្ធ សមាជិកទាំងអស់ប្រើទម្រង់មួយដែលរៀបចំដោយមជ្ឈមណ្ឌលស្រាវជ្រាវ និងព័ត៌មាន (RIC)។

- មជ្ឈមណ្ឌលស្រាវជ្រាវ និងព័ត៌មាន (RIC) ធ្វើយុទ្ធនាការប្រចាំឆ្នាំមួយដើម្បីធ្វើបច្ចុប្បន្នភាព និងផ្ទៀងផ្ទាត់ទិន្នន័យនៃករណីវិវាទដីធ្លីក្នុងទូទាំងប្រទេស។ យុទ្ធនាការនេះធ្វើឡើងដោយសហការជាមួយសមាជិកបណ្តាញ LAHRiN នៅតាមខេត្តនីមួយៗ និងត្រូវបានអនុវត្តក្នុងខែ វិច្ឆិកា រៀងរាល់ឆ្នាំ។

- មន្ត្រីផ្នែកច្បាប់នៃវេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា ធ្វើការចុះសិក្សាផ្ទាល់ដើម្បីផ្ទៀងផ្ទាត់ព័ត៌មានលម្អិតអំពីករណីវិវាទដីធ្លីទាំងឡាយ ដែលសមាជិកបណ្តាញ LAHRiN មិនអាចផ្ទៀងផ្ទាត់បាន។

### ៤.៣ ឧបករណ៍ប្រើប្រាស់ក្នុងការវិភាគស្ថិតិ

ទិន្នន័យនៃករណីវិវាទដីធ្លីទាំងអស់ដែលប្រមូលបាន ត្រូវបានកត់ត្រានៅក្នុងប្រព័ន្ធទិន្នន័យរបស់មជ្ឈមណ្ឌលស្រាវជ្រាវ និងព័ត៌មាន។ កម្មវិធីនានា រួមមាន កម្មវិធី Microsoft Excel, កម្មវិធីវិភាគទិន្នន័យ SPSS និងកម្មវិធីប្រព័ន្ធព័ត៌មានភូមិសាស្ត្រ (GIS) ត្រូវបានប្រើប្រាស់ដើម្បីវិភាគករណីទាំងនោះ និងផ្ដល់ទិដ្ឋភាពទូទៅនៃស្ថិតិវិវាទដីធ្លី និងទីតាំងភូមិសាស្ត្រនៃវិវាទទាំងនោះ។

### ៤.៤ ចំណុចខ្វះខាតនៃវិធីសាស្ត្រ

វិធីសាស្ត្រចំបងក្នុងរបាយការណ៍នេះ គឺពឹងផ្អែកភាគច្រើនទៅលើការប្រមូលព័ត៌មានអំពីការកើតឡើងនៃវិវាទដីធ្លីពីប្រភពសារព័ត៌មានផ្សេងៗ ដូច្នេះករណីវិវាទមួយចំនួនមិនបានចុះផ្សាយក្នុងប្រភពសារព័ត៌មានមិនបានកត់ត្រា។ ដើម្បីបំពេញនូវចំនុចខ្វះខាតនេះមជ្ឈមណ្ឌលស្រាវជ្រាវ និងព័ត៌មាន (RIC) បានព្យាយាម ប្រមូលទិន្នន័យ អំពីវិវាទដែលមិនត្រូវបានរាយការណ៍ក្នុងប្រភពសារព័ត៌មាន ពីសមាជិកបណ្ដាញ LAHRiN ។ ប៉ុន្តែ សមាជិកទាំងនេះមិនធ្វើសកម្មភាពនៅគ្រប់តំបន់ក្នុងប្រទេសទេ ហើយវិវាទអាចមិនត្រូវបានយកចិត្តទុកដាក់ដោយអ្នកនៅក្រៅតំបន់ជាប់នោះផងដែរ។

## ៥. លទ្ធផលនៃការវិភាគ

ទិន្នន័យ និងក្រាហ្វិកដែលបង្ហាញនៅក្នុងរបាយការណ៍នេះផ្អែកលើព័ត៌មានស្ដីពីវិវាទដីធ្លីដែលបានចេញផ្សាយដោយប្រព័ន្ធផ្សព្វផ្សាយក្នុងស្រុក និងជាទូទៅមិនរួមបញ្ចូលទិន្នន័យចំពោះករណីដែលគ្រប់គ្រងដោយគណៈកម្មការរដ្ឋបាល គណៈកម្មការសុរិយោដី ឬក្រុមប្រឹក្សាឃុំសង្កាត់។ លើកលែងករណីមួយចំនួនដែលគ្រប់គ្រងដោយស្ថាប័នទាំងនេះ បានចុះផ្សាយដោយប្រព័ន្ធផ្សព្វផ្សាយក្នុងស្រុក។

## ៥.១ វិវាទដីធ្លីគិតតាមឆ្នាំ

ជាសរុប ករណីវិវាទដីធ្លីថ្មីចំនួន ២៨[១៨] ដែលបំពេញលក្ខណៈវិនិច្ឆ័យនៃមជ្ឈមណ្ឌលស្រាវជ្រាវ និងព័ត៌មាន (RIC) ដែលបានបង្ហាញខាងលើ ត្រូវបានកត់ត្រាថាចាប់ផ្តើមក្នុងឆ្នាំ ២០១៣។ ចំនួននេះគឺមានលក្ខណៈទាបជាងធៀបទៅនឹងករណីវិវាទដែលបានកើតឡើងក្នុងឆ្នាំ២០១០, ២០១១ និង ២០១២ ដែលចំនួនវិវាទថ្មី ៣៩, ៣៩ និង ៤៦ ក្នុងឆ្នាំនីមួយៗ។

ទន្ទឹមនឹងការកត់ត្រាវិវាទថ្មី របាយការណ៍ក៏កត់ត្រាផងដែរនូវចំនួនវិវាទសរុប ដែលជាវិវាទដែលមិនត្រូវបានដោះស្រាយ និងដែលបានបន្តមកពីបណ្តាឆ្នាំមុន។ លើសពីនេះ ករណីវិវាទដីធ្លីចំនួនប្រាំមួយ ក៏បានដាក់បញ្ចូលក្នុងការវិភាគនេះផងដែរ[១៩] ប៉ុន្តែ វិវាទទាំងនេះមិនត្រូវបានរាយការណ៍នៅពេលវិវាទកើតឡើងនោះទេ វិវាទទាំងនេះផ្ទុះមុនឆ្នាំ ២០១៣។ ប្រការនេះធ្វើឲ្យចំនួនសរុបនៃវិវាទដីធ្លីក្នុងឆ្នាំ ២០១៣ កើនឡើងដល់ ៤០៥។ ក្នុងចំណោមវិវាទទាំងនេះ ៨១ ករណី ត្រូវបានដោះស្រាយក្នុងឆ្នាំ ២០១៣ និង ១៣ ករណីវិវាទដីធ្លីបានបោះបង់ការទាមទារ។ ជាលទ្ធផល ៧៧% ឬ ៣១១ ករណីនៃវិវាទដីធ្លីសរុបចំនួន ៤០៥ ដែលមិនទាន់បានដោះស្រាយទាំងស្រុងនៅឡើយគិតដល់ឆ្នាំ ២០១៣។




**រូបទី ១៖ និន្នាការវិវាទដីធ្លី – វិវាទថ្មីក្នុងមួយឆ្នាំៗ**

[១៨] សូមមើលឧបសម្ព័ន្ធទី ១។

[១៩] ការវិភាគស្ថិតិនៃរបាយការណ៍វិវាទដីធ្លីនៅកម្ពុជា, របាយការណ៍ឆ្នាំ ២០១២ លើកឡើងថា ៤៦ ករណីថ្មីបានកើតឡើងក្នុងឆ្នាំ ២០១២។

## ៥.២ វិវាទដីធ្លី និង ទីកន្លែងមានវិវាទ

ដូចបានបង្ហាញជូនខាងលើ មជ្ឈមណ្ឌលស្រាវជ្រាវ និងព័ត៌មាន (RIC) បានកំណត់ករណីវិវាទដីធ្លីសកម្មចំនួន ៣១១។ ករណីទាំងនេះ រួមមានករណីទាំងឡាយដែលមិនទាន់ដោះស្រាយទាំងស្រុង ដែលកំពុងស្ថិតក្នុងដំណើរការដោះស្រាយ និងករណីវិវាទដែល "ស្ងាត់" (បានន័យថាបណ្តឹងមួយត្រូវបានទទួលជាផ្លូវការ ប៉ុន្តែ នៅពុំទាន់មានចំណាត់ការដោយអាជ្ញាធរមានសមត្ថកិច្ច) ហើយករណីផ្សេងទៀតដែលនីតិវិធីដោះស្រាយនៅមិនទាន់មានលក្ខណៈច្បាស់លាស់។

រាជធានី/ខេត្តទាំង ២៤ នៃប្រទេសកម្ពុជាសុទ្ធតែរងផលប៉ះពាល់ពីវិវាទដីធ្លី។ វិវាទដីធ្លីបានកើតឡើងខ្ពស់បំផុតគឺនៅរាជធានីភ្នំពេញ ដែលមាន ២៩ ករណី បន្ទាប់នោះ មានខេត្តរតនគិរី និង ខេត្តកំពង់ស្ពឺ ដែលមាន ២៦ ករណី និង ២៤ ករណី ក្នុងខេត្តនីមួយៗតាមលំដាប់។ ដូចបានបង្ហាញជូនខាងក្រោមក្នុង រូបទី ២ ក៏ដូចជា ឧបសម្ព័ន្ធ "គ" តួលេខក៏បង្ហាញផងដែរថា ខេត្តទាំងពីរដែលមានករណីវិវាទដីធ្លីទាបជាងគេ គឺខេត្តប៉ៃលិន និងខេត្តកែប ដែលខេត្តនីមួយៗមានមួយករណី។




**រូបទី ២៖ ចំនួននៃវិវាទដីធ្លីតាមបណ្តាខេត្ត**

### ៥.២.១ ទីតាំងនៃវិវាទដីធ្លីនៅរាជធានីភ្នំពេញ

ក្នុងចំណោមវិវាទដីធ្លីចំនួន ២៤ ដែលកត់ត្រានៅរាជធានីភ្នំពេញ សង្កាត់/ ឃុំ ស្ទឹងមានជ័យ មានចំនួនវិវាទខ្ពស់ជាងគេដោយមានបីករណី។ ផែនទីខាងក្រោមបង្ហាញថាសង្កាត់បួនផ្សេងគ្នាមានពីរករណីវិវាទដីធ្លី ពោលគឺ បឹងកក់ពីរ វាលវង់ ព្រៃកប្រា និងស្រះចក ខណៈដែលសង្កាត់ដែលរងផលប៉ះពាល់ផ្សេងៗទៀតមានតែមួយករណី។

## ផែនទី ទី ១៖ វិវាទដីធ្លីនៅរាជធានីភ្នំពេញតាមសង្កាត់/ ឃុំ




### ៥.២.២ ទីតាំងនៃវិវាទដីធ្លីនៅខេត្តរតនគិរី

យោងតាមទិន្នន័យនៃមជ្ឈមណ្ឌលស្រាវជ្រាវ និងព័ត៌មាន (RIC) ក្នុងចំណោមវិវាទដីធ្លីចំនួន ៣១១ ករណីចំនួន ២៦ ត្រូវបានកត់ត្រាថាចាប់ផ្តើមនៅខេត្តរតនគិរី ដែលជាប់លំដាប់ទីពីរបន្ទាប់ពីរាជធានីភ្នំពេញ។ នៅខេត្តរតនគិរី សង្កាត់ពីរផ្សេងគ្នាមានវិវាទដីធ្លីចំនួនបីដូចជាសង្កាត់កិចុង និងលំផាត់ ហើយឃុំផ្សេងគ្នាចំនួនប្រាំមួយមានពីរករណី ខណៈដែលសង្កាត់រងផលប៉ះពាល់ប្រាំបួនផ្សេងទៀតមានមួយករណី។

### ផែនទី ទី ២៖ វិវាទដីធ្លីនៅខេត្តរតនគិរីតាមសង្កាត់/ឃុំ




## ៥.៣ ករណីវិវាទដីធ្លីដែលត្រូវបានដោះស្រាយតាមឆ្នាំ

ក្នុងចំណោមករណីវិវាទ ចំនួន ៤០៥ ករណី មាន ៨១[២០] ករណី ស្មើនឹង ២០% ត្រូវបានដោះស្រាយទាំងស្រុងក្នុងឆ្នាំ ២០១៣។ ករណីដែលបានដោះស្រាយ គឺជាវិវាទទាំងឡាយដែលកើតឡើងនៅក្នុងឆ្នាំកន្លងទៅ។ ជាឧទាហរណ៍មួយ ករណីវិវាទដីធ្លីមួយដែលបានកើតឡើងក្នុងឆ្នាំ ១៩៩៥ នៅភូមិព្រៃកតានប់ ឃុំកំពង់ស្វាយ ស្រុកកៀនស្វាយ ខេត្តកណ្តាល ដែលទើបតែបានដោះស្រាយក្នុងឆ្នាំ ២០១៣ ហើយករណីផ្សេងទៀត ដូចជាករណីវិវាទមួយនៅភូមិកៃវផុស ឃុំជ្រោយស្វាយ ស្រុកស្រែអំបិល ខេត្តកោះកុង ដែលបានកើតឡើងក្នុងឆ្នាំ ២០០៥ ក៏ទើបតែបានដោះស្រាយក្នុងឆ្នាំ ២០១៣ ដែរ។ រូបទី ៣ ខាងក្រោមបង្ហាញថាករណីវិវាទដីធ្លីចំនួន ១២ ដែលកើតឡើងក្នុងឆ្នាំ ២០១១ បានដោះស្រាយ

[២០] សូមមើលឧបសម្ព័ន្ធទី ២

ក្នុងឆ្នាំ ២០១៣។ ក្នុងឆ្នាំ ២០១២ វិវាទដីធ្លីត្រូវបានដោះស្រាយបានច្រើនជាងក្នុងបណ្តាឆ្នាំផ្សេងទៀត។




**រូបទី ៣៖ កាលបរិច្ឆេទនៃការកើតឡើងនៃវិវាទដីធ្លីដែលបានដោះស្រាយក្នុងឆ្នាំ ២០១៣**

គេគប្បីកត់សម្គាល់នៅទីនេះថាមជ្ឈមណ្ឌលស្រាវជ្រាវ និងព័ត៌មាន (RIC) មិនមានយោបល់អំពីភាពគ្រប់គ្រាន់នៃកិច្ចដំណើរការដោះស្រាយវិវាទ ឬលទ្ធផលបានទេ ពោលគឺអាចត្រឹមតែមានយោបល់ថាវិវាទត្រូវបានដោះស្រាយឲ្យភាគីមួយ ឬភាគីម្ខាងទៀតឈ្នះ ឬថាដំណោះស្រាយមួយត្រូវបានចរចារ។

ករណីវិវាទដីធ្លីចំនួន ៣២៨ បានដោះស្រាយចាប់តាំងពីឆ្នាំ ២០០៧ ដល់ឆ្នាំ ២០១៣។ តួលេខនេះ បង្ហាញពីកំណើនចំនួននៃករណីដែលបានដោះស្រាយចាប់តាំងពីឆ្នាំ ២០១០ ហើយដែលក្នុងឆ្នាំ ២០១២ មានការកើនឡើងខ្លាំង ដោយមាន ១០៨ ករណីបានដោះស្រាយ មុនពេលបោះឆ្នោតជាតិក្នុងខែ កក្កដា ឆ្នាំ ២០១៣ ដែលគឺជាកំណើនដ៏សំខាន់មួយលើក្នុងតួលេខសម្រាប់ឆ្នាំ ២០១២ (សូមមើលរូបទី ៤)។

ស្ថិតិបង្ហាញថាវិវាទដីធ្លីភាគច្រើន ពោលគឺ ១៧ % ឬ ១៤ នៃ ៨១ ករណី ត្រូវបានដោះស្រាយដោយអាជ្ញាធរមូលដ្ឋាន។ ស្ថិតិក៏បង្ហាញផងដែរថា ១៦% ឬ ១៣ ករណីដែលបានដោះស្រាយ ទាក់ទិននឹងបទបញ្ញាលេខ ០០១ ដោយសារដីមានវិវាទត្រូវបានកំណត់ព្រំដីដោយមានការយល់ព្រមពីភាគីវិវាទ។




**រូបទី ៤៖ ករណីវិវាទដីធ្លីដែលបានដោះស្រាយតាមឆ្នាំនីមួយៗ**

## ៥.៤ ដំណោះស្រាយករណីវិវាទដីធ្លី

### ៥.៤.១ ស្ថាប័នទទួលពាក្យបណ្តឹង

ភាគីវិវាទទាំងអ្នកកាន់កាប់ដីដើម ទាំងភាគីទីពីរ បានដាក់បណ្តឹងរបស់ខ្លួនទៅកាន់ស្ថាប័នតុលាការ និងស្ថាប័នរដ្ឋផ្សេងៗ។ ជាសរុប មានបណ្តឹងចំនួន ៨៦៥ បណ្តឹង។ បណ្តឹងវិវាទដីធ្លីខ្លះបានដាក់ជូនស្ថាប័នរាជរដ្ឋាភិបាល រួមមានអាជ្ញាធរមូលដ្ឋាន ទាំងនៅកម្រិតឃុំ/សង្កាត់ និងស្រុក/ខណ្ឌ គណៈកម្មការសុរិយោដី សាលារាជធានី/ខេត្ត តុលាការ ព្រមទាំងនៅស្ថាប័នថ្នាក់ជាតិដែលនឹងរាយនាមនៅក្នុងកថាខណ្ឌបន្ទាប់នេះ។ គួរកត់សំគាល់ថាបណ្តឹងភាគច្រើនចំនួន ២៤០ បានដាក់ជូនអាជ្ញាធរមូលដ្ឋាន។ បណ្តឹងចំនួន ១៣៧ ត្រូវបានដាក់ជូនសាលារាជធានី/ខេត្ត។ ជាងនេះទៅទៀត បណ្តឹងចំនួន ២៧ បានដាក់ជូនគណៈកម្មការសុរិយោដីស្រុក/ខណ្ឌ ៤៧ ករណីដាក់ជូនគណៈកម្មការសុរិយោដីរាជធានី/ខេត្ត និង ២០ ករណីដាក់ជូនគណៈកម្មការសុរិយោដីជាតិ។ បណ្តឹងជាច្រើនក៏បានដាក់ជូនផងដែរនៅកម្រិតផ្សេងៗគ្នានៃប្រព័ន្ធតុលាការ ដែលបណ្តឹងចំនួន ៧២ បានដាក់ជូនសាលាដំបូងរាជធានី/ខេត្ត ២៥ បណ្តឹងនៅសាលាឧទ្ធរណ៍ និង ១៦ បណ្តឹងនៅតុលាការកំពូល។ ដោយសារជារឿយៗ

តុលាការខកខានមិនបានចេញសេចក្តីសម្រេច ឬ ទទួលករណីដើមបណ្តឹង ច្រើនតែដាក់បណ្តឹងរបស់ខ្លួនជូនស្ថាប័នក្រៅប្រព័ន្ធតុលាការ ដែលបណ្តឹងចំនួន ២២ បានផ្ញើរជូនអាជ្ញាធរជាតិដោះស្រាយវិវាទដីធ្លី (NALDR)។ បណ្តឹងចំនួន ៤០ បានផ្ញើរជូនខុទ្ទកាល័យនាយករដ្ឋមន្ត្រី, ២៤ បណ្តឹង ផ្ញើរជូន ក្រសួងមហាផ្ទៃ, ២០ បណ្តឹង ផ្ញើរជូនគណៈរដ្ឋមន្ត្រី, ៤៦ បណ្តឹង ផ្ញើរជូនរដ្ឋសភា និង ១០ បណ្តឹងបានដាក់ជូនព្រះបរមរាជវាំង។

| ស្ថាប័ន | វិវាទដីធ្លី |
|---|---|
| អាជ្ញាធរមូលដ្ឋាន | ២៤០ |
| គណៈកម្មការសុរិយោដីស្រុក/ខណ្ឌ | ២៧ |
| គណៈកម្មការសុរិយោដីរាជធានី/ខេត្ត | ៤៧ |
| គណៈកម្មការសុរិយោដីថ្នាក់ជាតិ | ២០ |
| អាជ្ញាធរជាតិដោះស្រាយវិវាទដីធ្លី | ២២ |
| សាលាដំបូងរាជធានី/ខេត្ត | ៧២ |
| សាលាឧទ្ធរណ៍ | ២៥ |
| តុលាការកំពូល | ១៦ |
| រដ្ឋសភា | ៤៦ |
| ព្រះបរមរាជវាំង | ១០ |
| ក្រសួងមហាផ្ទៃ | ២៤ |
| ទីស្តីការគណៈរដ្ឋមន្ត្រី | ២០ |
| ខុទ្ទកាល័យនាយករដ្ឋមន្ត្រី | ៤២ |
| សាលារាជធានី/ខេត្ត | ១៣៧ |
| ក្រសួងទំនាក់ទំនងរដ្ឋសភា ព្រឹទ្ធសភា និង អធិការកិច្ច | ២០ |
| ស្ថាប័នផ្សេងទៀត | ៩៧ |
| **សរុប** | ៨៦៥ |

### ៥.៤.២ ដំណើរការដោះស្រាយវិវាទ

ចាប់តាំងពីដើមទសវត្សរ៍ឆ្នាំ ១៩៩០ ករណីវិវាទដីធ្លីចំនួន ៤០៥ បានឆ្លងកាត់ដំណើរការដោះស្រាយ ហើយករណីខ្លះបានដោះស្រាយទាំងស្រុង ឬ ករណីខ្លះទៀតបានដោះស្រាយមួយផ្នែក ឬករណីមួយចំនួនកំពុងដំណើរការដោះស្រាយ។ ក្នុងឆ្នាំ ២០១៣ វិវាទចំនួន ៨១ ត្រូវបានដោះស្រាយទាំងស្រុង, ១៧៩ ករណី មិនទាន់បានដោះស្រាយ ខណៈដែល ១២២ ករណី បានដោះស្រាយមួយផ្នែក (ឧទាហរណ៍ វិវាទមួយដែលពាក់ព័ន្ធគ្រួសារច្រើន ដំណោះស្រាយបានដោះស្រាយជូនគ្រួសារមួយចំនួន ប៉ុន្តែមិនមែនដោះស្រាយជូនគ្រួសាររងផលប៉ះពាល់ទាំងអស់ទេ)។ វិវាទដីធ្លី ៤៣ ករណី ឬ ១១% បានដោះស្រាយ ឲ្យភាគីទីពីរជាអ្នកឈ្នះ និងមានតែ ១៥ ករណី ឬ ៤% ភាគរយប៉ុណ្ណោះដែលបានដោះស្រាយឲ្យអ្នកកាន់កាប់ដីដើមជាអ្នកឈ្នះ។ ករណីចំនួន ១៦ ឬ ៤% បានដោះស្រាយដោយការស្រុះស្រួលគ្នារវាងភាគីវិវាទ ខណៈដែល ៧ ករណី ឬ ២% ត្រូវបានដោះស្រាយដោយការផ្តល់សំណង។ ករណីចំនួន ១៣ ឬ ៣% បានបោះបង់ដោយភាគីវិវាទ។

ក្នុងចំណោមករណីសេសសល់ចំនួន ១៦២ (៥៧% នៃចំនួនសរុប) ដែលមិនទាន់មានចំណាត់ការដោះស្រាយផ្លូវការណាមួយនោះ ទោះបីជាបណ្តឹងបានដាក់ជូនអាជ្ញាធរ ឬតុលាការក៏ដោយ។ ករណីចំនួន ១៥ ឬ ៥% បានកត់ត្រាថាមានលក្ខណៈ "ស្ងាត់ស្ងៀម" និង ២០ ករណី ឬ ៧% បានបោះបង់ចោលការទាមទារ(ព័ត៌មានលម្អិតមាននៅក្នុងឧបសម្ព័ន្ធ៤)។

ក្នុងចំណោមវិវាទដីធ្លីចំនួន ២០០ ដែលជាដីកសិកម្ម មានតែ ៤៧ ករណី ឬ ២៣.៥% ប៉ុណ្ណោះដែលបានដោះស្រាយទាំងស្រុង ខណៈករណីវិវាទចំនួន ១១២ ករណីដែលជាដីលំនៅឋានមានតែ ១៥ ករណី ឬ ១៣.៣៩% បានដោះស្រាយទាំងស្រុង។

| ស្ថានភាពវិវាទដីធ្លី | ករណីវិវាទដីធ្លី | ភាគរយ (%) |
|---|---|---|
| មិនដឹង | ២ | ០ |
| មិនបានដោះស្រាយ | ១៧៩ | ៤៤ |
| បានដោះស្រាយមួយផ្នែក | ១២២ | ៣០ |
| *បានដោះស្រាយជូនអ្នកកាន់កាប់ដីដើម* | *៤៣* | *១១* |
| *បានដោះស្រាយជូនភាគីទីពីរ* | *១៥* | *៤* |
| *បានដោះស្រាយជូនទាំងអ្នកកាន់កាប់ដីដើមនិងភាគីទីពីរ* | *១៦* | *៤* |
| *បានដោះស្រាយដោយផ្តល់សំណង* | *៧* | *២* |
| បានបោះបង់ការទាមទារ | ១៣ | ៣ |
| ស្ងាត់ស្ងៀម | ៨ | ២ |
| ករណីវិវាទដីធ្លីសរុប | ៤០៥ | ១០០% |

**តារាងទី ១៖ លទ្ធផលនៃការដោះស្រាយវិវាទដីធ្លី**

| ប្រភេទដី | ស្ថានភាពនៃដំណោះស្រាយ | | | | | | សរុប | ភាគរយ |
|---|---|---|---|---|---|---|---|---|
| | ដោះស្រាយទាំងស្រុង | ដោះស្រាយមួយផ្នែក | ពុំទាន់មានចំណាត់ការដំណោះស្រាយ/ពុំបានដោះស្រាយ | ស្ងាត់ស្ងៀម | បោះបង់ការទាមទារ | មិនដឹង | | |
| ដីកសិកម្ម | ៤៧ | ៥៦ | ៧៩ | ៧ | ៩ | ២ | ២០០ | ៤៩% |
| ដីព្រៃ(ព្រៃសហគមន៍) | ៤ | ៨ | ១៩ | ១ | ១ | | ៣៣ | ៨% |
| ដីព្រៃ(ដីរបស់រដ្ឋ) | ៥ | ៤ | ៥ | ០ | ០ | ០ | ១៤ | ៣% |
| ដីលំនៅឋាន | ១៥ | ៣៨ | ៥៧ | ០ | ២ | ០ | ១១២ | ២៨% |
| ដីសើម | ០ | ២ | ១ | ០ | ០ | ០ | ៣ | ១% |
| ផ្សេងទៀត | ៨ | ១១ | ១៣ | ០ | ១ | ០ | ៣៣ | ៨% |
| មិនដឹង | ២ | ៣ | ៥ | ០ | ០ | ០ | ១០ | ២% |
| សរុប | ៨១ | ១២២ | ១៧៩ | ៨ | ១៣ | ២ | ៤០៥ | ១០០ |
| ភាគរយ | ២០% | ៣០% | ៤៤% | ២% | ៣% | ០ | ១០០ | |

**តារាងទី ២៖ ដំណើរការដោះស្រាយវិវាទ**

## ៥.៥ គ្រួសារដែលរងផលប៉ះពាល់ពីវិវាទដីធ្លី

ទិន្នន័យរបស់មជ្ឈមណ្ឌលស្រាវជ្រាវ និងព័ត៌មាន (RIC) បង្ហាញថាវិវាទដីធ្លីចំនួន ៣១១ ដែលកំពុងកើតមានក្នុងនោះរួមមានករណីកើតថ្មីចំនួន ៣៨ ដែលបានកត់ត្រាក្នុងឆ្នាំ ២០១៣ ក៏ដូចជាករណីពីបណ្តាឆ្នាំមុនៗ ដែលនៅមិនទាន់បានដោះស្រាយ។ ទិន្នន័យបង្ហាញថា ករណីវិវាទទាំង ៣១១ នេះប៉ះពាល់គ្រួសារចំនួន ៦៥,៨៦៧។ យោងតាមស្ថិតិប្រជាសាស្រ្តផ្លូវការកម្ពុជា ទំហំគ្រួសារមធ្យមមានសមាជិក ៤.៧ នាក់[២១] ដូច្នេះ គេអាចប៉ាន់ស្មានបានថា វិវាទទាំងនេះប៉ះពាល់ប្រជាជនរហូតដល់ ៣០៩,៥៧៥ នាក់។ តួលេខនេះ គឺស្មើនឹងប្រហែល ២.៣៤% នៃចំនួនគ្រួសារសរុបក្នុងទូទាំងប្រទេស។[២២] ការវិភាគទិន្នន័យនៃមជ្ឈមណ្ឌលស្រាវជ្រាវ និងព័ត៌មាន (RIC) បង្ហាញថារាជធានីភ្នំពេញ និងខេត្តកំពង់ចាម មានចំនួនគ្រួសាររងផលប៉ះពាល់ខ្ពស់ជាងគេ ដែលមានចំនួន ១៥,២៤៦ នៅរាជធានីភ្នំពេញ និង ៥,៩៥៣ គ្រួសារនៅខេត្តកំពង់ចាម។ តារាងខាងក្រោមបង្ហាញតួលេខនៃគ្រួសាររងផលប៉ះពាល់តាមបណ្តាខេត្តទាំងអស់ ដែលចំណាត់ថ្នាក់របស់ខេត្តនីមួយៗចាប់ពីចំនួនប្រជាជនរងផលប៉ះពាល់ខ្ពស់បំផុតដល់ទាបបំផុត។

| ល.រ | ខេត្ត | ចំនួនវិវាទដី | ចំនួនគ្រួសារ | ល.រ | ខេត្ត | ចំនួនវិវាទដី | ចំនួនគ្រួសារ |
|---|---|---|---|---|---|---|---|
| ១ | រាជធានីភ្នំពេញ | ២៩ | ១៥២៤៦ | ១៣ | កណ្តាល | ៧ | ២០៨០ |
| ២ | កំពង់ចាម | ២១ | ៥៩៥៣ | ១៤ | កោះកុង | ១៥ | ១៨៩៩ |
| ៣ | ក្រចេះ | ៨ | ៤៧៤៥ | ១៥ | ព្រះសីហនុ | ១៥ | ១៨៨២ |
| ៤ | បន្ទាយមានជ័យ | ២២ | ៤៣៧០ | ១៦ | ឧត្តរមានជ័យ | ១០ | ១៨៧២ |
| ៥ | ពោធិ៍សាត់ | ២០ | ៤២៤៣ | ១៧ | បាត់ដំបង | ១៣ | ១៥១២ |
| ៦ | មណ្ឌលគិរី | ១៥ | ៣២៣២ | ១៨ | កំពង់ធំ | ៥ | ១១៩២ |
| ៧ | ព្រះវិហារ | ១៧ | ២៧៩៤ | ១៩ | កំពង់ឆ្នាំង | ៩ | ៨៧៦ |

[២១] ជំរឿនចំនួនប្រជាជនទូទៅកម្ពុជា ឆ្នាំ ២០០៨ វិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការ រាជធានីភ្នំពេញ កម្ពុជា ខែ សីហា ឆ្នាំ ២០០៨ ទំព័រ VI, មាននៅ៖ http://www.stat.go.jp/english/info/meetings/cambodia/pdf/pre_rep1.pdf។

[២២] យោងតាមរបាយការណ៍ជាតិស្តីពីស្ថិតិឆ្នាំ ២០០៨ ចំនួនគ្រួសារសរុបក្នុងទូទាំងប្រទេសកម្ពុជា គឺ ២,៨១៧,៦៣៧ ហើយចំនួនប្រជាជនសរុប គឺ ១៣,៣៩៥,៦៨២ នាក់។ ស្ថិតិមាននៅ៖ http://www.nis.gov.kh/។

| | | | | | | | |
|---|---|---|---|---|---|---|---|
| ៨ | កំពង់ស្ពឺ | ២៤ | ២៦៧០ | ២០ | ព្រៃវែង | ៥ | ៦៥៣ |
| ៩ | រតនគិរី | ២៦ | ២៦៦២ | ២១ | តាកែវ | ៦ | ៤០៨ |
| ១០ | ស្វាយរៀង | ១៨ | ២៥៨៣ | ២២ | ក្រុងប៉ៃលិន | ១ | ៣៤៥ |
| ១១ | ស្ទឹងត្រែង | ៦ | ២៣២៦ | ២៣ | កំពត | ៣ | ១៩៣ |
| ១២ | សៀមរាប | ១៥ | ២១០០ | ២៤ | ក្រុងកែប | ១ | ៣១ |
| | | | | | | សរុប | ៦៥៨៦៧ |

តារាងទី ៣: គ្រួសាររងផលប៉ះពាល់តាមបណ្តាខេត្ត

នៅពេលដែលករណីទាំងឡាយ ត្រូវបានបែងចែកតាមចំនួនគ្រួសារដែលរងផលប៉ះពាល់ គេអាចមើលឃើញថា ៥៣ %, ឬ ១៦៥ ករណី ដែលពាក់ព័ន្ធនឹងគ្រួសារចាប់ពី ៥ ដល់ ១០០ គ្រួសារ។ ករណីចំនួន ៥៨ ឬ ១៩% ដែលពាក់ព័ន្ធនឹងគ្រួសារចាប់ពី ១០១ ដល់ ២០០ គ្រួសារ។ ករណីចំនួន ១១ ឬ ៤% នៃវិវាទទាំងអស់ ដែលពាក់ព័ន្ធនឹងគ្រួសារលើសពី ១០០០ គ្រួសារ។

| ចំនួនគ្រួសារដែលរងផលប៉ះពាល់ពីវិវាទដីធ្លី | | |
|---|---|---|
| ចំនួនគ្រួសារ | ចំនួនករណីវិវាទដីធ្លី | ភាគរយ (%) |
| ៥-១០០ | ១៦៥ | ៥៣ |
| ១០១-២០០ | ៥៨ | ១៩ |
| ២០១-៣០០ | ២៩ | ៩ |
| ៣០១-៤០០ | ១៧ | ៥ |
| ៤០១-៥០០ | ៩ | ៣ |
| ៥០១-៦០០ | ៤ | ១ |
| ៦០១-៧០០ | ៧ | ២ |
| ៧០១-៨០០ | ៥ | ២ |
| ៨០១-១០០០ | ២ | ១ |
| >១០០០ | ១១ | ៤ |
| មិនដឹង | ៤ | ១ |
| សរុប | ៣១១ | ១០០% |

តារាងទី ៤: ចំនួនគ្រួសាររងផលប៉ះពាល់ពីវិវាទដីធ្លី

## ៥.៦ ប្រភេទដីដែលមានវិវាទ

វិវាទដីធ្លីបានកើតឡើងលើប្រភេទដីផ្សេងៗគ្នា រួមមាន ដីកសិកម្ម (ដីស្រែចម្ការ និងដីស្រែ) ដីលំនៅឋាន(ដីភូមិ) ដីព្រៃ (រួមទាំងដីសហគមន៍ព្រៃឈើ) និងដីប្រភេទផ្សេងទៀត ដូចជាដីសើម ផ្លូវថ្មើរជើង ដីព្រៃលិចទឹក និងដីដែលជាកម្មសិទ្ធិរបស់វត្ត។ លទ្ធផលនៃការវិភាគនេះបង្ហាញថាដីកសិកម្មគឺជាប្រភេទដីដែលមានជម្លោះច្រើនជាងគេ ដែលបន្ទាប់នោះ មានដីលំនៅឋាន និងដីព្រៃ។




**រូបទី ៥៖ ប្រភេទដីដែលរងផលប៉ះពាល់ពីវិវាទដីធ្លី**

ទំហំមធ្យមនៃដីពាក់ព័ន្ធក្នុងវិវាទដីធ្លី គឺ ៦៧ ហិកតា ខណៈដែលករណីធំបំផុតពាក់ព័ន្ធនឹងដីទំហំរហូតដល់ ៣០០ ហិកតា នៃដីលំនៅឋាននៅខេត្តព្រះវិហារ ដែលពាក់ពន្ធនឹងតំបន់ជុំវិញប្រាសាទព្រះវិហារ។ ករណីតូចបំផុតដែលពាក់ព័ន្ធផ្ទៃដីត្រឹមតែ ០.០៦ ហិកតា នៃដីលំនៅឋាន រួមទាំងដីការិយាល័យប្រជុំប្រចាំភូមិ និងដីស្រះទឹក បានកើតឡើងនៅរាជធានីភ្នំពេញ។

នៅក្នុងទូទាំងប្រទេស ផ្ទៃដីទំហំ ១៨៨,៤៣៥ ហិកតា ជាប់ពាក់ព័ន្ធក្នុងវិវាទ ដែលនៅក្នុងនោះ ផ្ទៃដីកសិកម្មមានទំហំ ៩១,៣២៣ ហិកតា ឬ ៤៨% ខណៈដែលដីលំនៅឋានមានវិវាទមានទំហំ ៥៤,៤២០ ហត ឬ ២៩%។

| ល | ប្រភេទដី | ទំហំដី (ហត) | % |
|---|---|---|---|
| ១ | ដីកសិកម្ម | ៩១,៣២៣ | ៤៨ |
| ២ | ដីលំនៅឋាន | ៥៤,៤២០ | ២៩ |
| ៣ | ដីព្រៃ (ដីសហគមន៍ព្រៃឈើ) | ៣២,៤៨៦ | ១៧ |
| ៤ | ដីសើម | ១៩៧ | ០ |
| ៥ | ដីប្រភេទផ្សេងទៀត | ៤,៧០៧ | ២ |
| ៦ | មិនដឹង | ៥,៣០២ | ៣ |
| **សរុប** | | ១៨៨,៤៣៥ | ១០០ |

ដូចបានបង្ហាញនៅក្នុងតារាងខាងលើ ករណីវិវាទដីធ្លីភាគច្រើនប៉ះពាល់លើដីកសិកម្ម។ ករណីវិវាទជាច្រើនដែលប៉ះពាល់លើដីកសិកម្មនេះ ដែលប្រើសប្រាស់ម្រាប់គោលបំណងផលិតកម្មកសិកម្មមុនពេលមានវិវាទ ហើយវិវាទទំនងជាមានផលប៉ះពាល់អវិជ្ជមានលើជីវភាពរបស់អ្នកកាន់កាប់ដី ឬ លើជីវិតប្រចាំថ្ងៃរបស់សហគមន៍ទាំងឡាយដែលរងផលប៉ះពាល់។ ចំណុចនេះគឺជាកង្វល់ដោយឡែកមួយ ចំពោះករណីដែលវិវាទដីធ្លីបានកើតឡើងអស់រយៈពេលដ៏យូរដោយគ្មានដំណោះស្រាយ។ ដូចដែលបានលើកឡើងខាងដើមនៃរបាយការណ៍នេះ ប្រការនេះអាចគឺជាឧបសគ្គមួយចំពោះការសម្រេចបាននូវគោលដៅកាត់បន្ថយភាពក្រីក្រនៃរាជរដ្ឋាភិបាលកម្ពុជា។

ខេត្តដែល មានតួលេខខ្ពស់បំផុតសម្រាប់វិវាទដីធ្លីលើដីកសិកម្ម គឺខេត្តបន្ទាយមានជ័យ បាត់ដំបង រតនគិរី កំពង់ចាម កំពង់ស្ពឺ និងសៀមរាប ដែលមានជាង ៥០% នៃករណីវិវាទពាក់ព័ន្ធនឹងដីកសិកម្ម (សូមមើលឧបសម្ព័ន្ធ ខ)។

## ៥.៧ មូលហេតុនៃវិវាទដីធ្លី

ផ្អែកលើការវិភាគទិន្នន័យនៃមជ្ឈមណ្ឌលស្រាវជ្រាវ និងព័ត៌មាន (RIC) គេអាចមើលឃើញថាមានមូលហេតុផ្សេងៗគ្នាដែលបង្ករឲ្យមានវិវាទដីធ្លី។ ផ្អែកលើលទ្ធផលនៃការវិភាគនេះ ២៦% ឬ ៨០ ករណីនៃវិវាទដីធ្លីដែលកើតឡើងក្រោយពេលដែលដីត្រូវបានទាមទារយកធ្វើជាដីសម្បទានសេដ្ឋកិច្ចដោយក្រុមហ៊ុនឯកជនមួយ។ ចំណែកឯករណីចំនួន ៤៥ នៃករណីវិវាទដីធ្លីទាំង ៨០ នេះពាក់ព័ន្ធនឹង "អ្នកមាន និងអ្នកមានអំណាច" ដែលទាមទារយកដីរបស់អ្នកកាន់កាប់ដីដើម។[២៣] វិវាទដីធ្លីចំនួន ១៤ ករណី ដែលទាក់ទិននឹងសម្បទានដីសេដ្ឋកិច្ចបណ្តាលប្រជាពលរដ្ឋមួយចំនួនត្រូវបានឃាត់ខ្លួន។




**រូបទី ៦៖ មូលហេតុនៃវិវាទដីធ្លី**

[២៣] សម្រាប់គោលបំណងនៃរបាយការណ៍នេះ "អ្នកកាន់កាប់ដីដើម" សំដៅលើគជន ឬជនទាំងឡាយដែលបានប្រើ ឬ បានគ្រប់គ្រងដីមានវិវាទមុនពេលចាប់ផ្តើមមានវិវាទ។

## ៥.៨ វិធីសាស្ត្រដែលប្រើប្រាស់ដើម្បីធ្វើលទ្ធកម្មដី

ភាគីទីពីរដែលព្យាយមទាមទារដីមានវិវាទ ប្រើប្រាស់នូវមធ្យោបាយផ្សេងៗក្នុងការទាមទារដី។[២៤] ករណីវិវាទដីធ្លីមួយចំនួន បង្ហាញថាភាគីទីពីរប្រើប្រាស់មានឯកសារមានការគាំទ្រ ឬលិខិតអនុញ្ញាតពីអាជ្ញាធរមូលដ្ឋាន ក្នុងការទាមទារដី–ឯកសារដែលប្រើប្រាស់ក្នុងការទាមទារដើម្បីទទួលបានដីមានលក្ខណៈមិនត្រឹមត្រូវ។ ការវិភាគរកឃើញថា ករណីវិវាទខ្លះប្រើប្រាស់នូវអំណាច ឬ ឥទ្ធិពលរបស់ខ្លួនដើម្បីទាមទារដីវិវាទ ផងដែរ។ ករណីខ្លះពាក់ព័ន្ធជាមួយអាជ្ញាធរមូលដ្ឋាន ដែលពួកគេគាំទ្រការទាមទាររបស់ភាគីទីពីរចំពោះការទាមទារដី ដោយមិនមានធ្វើការស៊ើបអង្កេតសមស្របឡើយ។

- ភាគីទីពីរបង្ហាញលិខិតអនុញ្ញាតពីអាជ្ញាធរ
- ការបំពានដោយប្រើអំណាចដោយមន្ត្រីរាជរដ្ឋាភិបាល និងអ្នកដែលមានទំទាក់ទំនងល្អជាមួយអ្នកជំនួយធំៗ
- ការគម្រាមកំហែងដល់អ្នកកាន់កាប់ដីដើម
- ការប្រើអំពើហិង្សាដល់អ្នកកាន់កាប់ដីដើម
- អ្នកកាន់កាប់ដីដើម ត្រូវបានឃាត់ខ្លួន




**រូបទី ៧៖ យុទ្ធសាស្ត្រធ្វើលទ្ធកម្មដី**

[២៤] សម្រាប់គោលបំណងនៃរបាយការណ៍នេះ "ភាគីទីពីរ" សំដៅលើអ្នកដែលកំពុងព្យាយាមទាមទារដីរបស់អ្នកកាន់កាប់ដីដើម។

ក្នុងចំណោមវិវាទដីធ្លីចំនួន ៣១១ ដែលកំពុងកើតមាន ១៨៧ ករណីពាក់ព័ន្ធមន្ត្រីរាជរដ្ឋាភិបាល និងអ្នកដែលមានទំនាក់ទំនងល្អជាមួយអ្នកជំនួយធំៗ, ១២៦ ករណីកើតមានការគម្រាមកំហែង, និង ៧៨ ករណីមានប្រើអំពើហិង្សា។ ករណីចំនួន ១១៣ បានប្តឹងតាមប្រព័ន្ធតុលាការ ហើយនៅក្នុង ៣៥ ករណីនៃករណីទាំងនេះ ប្រជាជនដែលពាក់ព័ន្ធក្នុងវិវាទត្រូវបានចាប់ខ្លួន និងដាក់ពន្ធនាគារនៅក្នុងដំណាក់កាលផ្សេងៗនៃវិវាទ[២៥]។ ដោយឡែកករណីវិវាទចំនួន ៦២ ការទាមទារដីគឺធ្វើដោយគ្មានឯកសារគាំទ្រ។




**រូបទី ៨ : ឯកសារដែលប្រើប្រាស់ដើម្បីទាមទារការកាន់កាប់ ឬ កម្មសិទ្ធិ**

## ៦. ការកាន់កាប់ដីកំពុងមានវិវាទបច្ចុប្បន្ន

នៅក្នុងវិវាទដីធ្លីភាគច្រើន នៅពេលដែលវិវាទកំពុងកើតមាន និងកំពុងរង់ចាំដំណោះស្រាយ អ្នកកាន់កាប់ដីដើមបានបន្តកាន់កាប់ ឬ ប្រើដីកំពុងមានបញ្ហា។ ក្នុង ១១៦ ករណី ឬ ៣៧% ដីនៅតែត្រូវបានកាន់កាប់ដោយអ្នកកាន់កាប់ដីដើម ខណៈដែល ៩៣ វិវាទដីធ្លី ឬ ៣០% នៃ

[២៥] ស្ថិតិនេះមិនបង្ហាញព័ត៌មានអំពីពេលណាដែលជនណាម្នាក់ត្រូវបានឃាត់ខ្លួន។ វាអាចកើតមាននៅក្នុងដំណាក់កាលផ្សេងៗនៃវិវាទ។

ករណីសរុប ដីបានបន្តកាន់កាប់ដោយភាគីទីពីរ ទោះបីជាវិវាទកំពុងកើតឡើងក្តី។ ក្នុង ៥៨ ករណី ឬ ១៩% ដីត្រូវបានកត់ត្រាថាត្រូវបានកាន់កាប់រួមដោយភាគីទាំងពីរ។

ចំពោះករណីវិវាទចំនួន ១៣ ដែលបាន "បោះបង់ការទាមទារ" ក្នុងចំណុច ៤.៥.២ ខាងលើ ១២ ករណីត្រូវបានកាន់កាប់ និងគ្រប់គ្រងដោយអ្នកកាន់កាប់ដីដើម ហើយដីតែក្នុង ១ ករណីប៉ុណ្ណោះ ត្រូវបានកាន់កាប់ដោយភាគីទីពីរ។

| ស្ថានភាពនៃការកាន់កាប់ដីមានវិវាទ | | |
|---|---|---|
| ស្ថានភាពកាន់កាប់ | ចំនួនវិវាទដីធ្លី | ភាគរយ (%) |
| ភាគីទីពីរកាន់កាប់ | ៩៣ | ៣០ |
| អ្នកកាន់កប់ដីដើមកាន់កាប់ | ១១៦ | ៣៧ |
| កាន់កាប់ដោយភាគីទាំងពីរ | ៥៨ | ១៩ |
| មិនដឹង | ៤៤ | ១៤ |
| សរុប | ៣១១ | ១០០ |

**តារាងទី ៤៖ ស្ថានភាពនៃប្រជាពលរដ្ឋដែលរស់នៅលើដីមានវិវាទ**

## ៧. វិវាទដីធ្លីដែលបណ្តាលមកពីសម្បទានដីសេដ្ឋកិច្ច

ផ្អែកលើលទ្ធផលនៃការវិភាគនេះ ៨០ ករណី ឬ ២៥% នៃវិវាទដីធ្លីសរុប ជាប់ទាក់ទិននឹងការផ្តល់សម្បទានដីសេដ្ឋកិច្ច។ សម្បទានទាំងនេះ ផ្តល់សម្រាប់គោលបំណងកសិ-ឧស្សាហកម្ម ដូច្នេះ តួលេខនេះមិនរាប់បញ្ចូលសម្បទានដែលត្រូវបានផ្តល់សម្រាប់គោលបំណងសង្គម និងគោលបំណងផ្សេងទៀតទេ។

ករណីវិវាទដីធ្លី ដែលបណ្តាលមកពីសម្បទានដីសេដ្ឋកិច្ចមានច្រើនជាងគេនៅប៉ែកបូព៌ានៃប្រទេស ហើយតំបន់ទាំងនោះជាទូរទៅគេដាំដើមកៅស៊ូ។ ករណីវិវាទបែបនេះជាង ១២ ករណីកើតមាននៅខេត្តមណ្ឌលគិរី និង ១១ ករណីកើតមាននៅខេត្តរតនគិរី ខណៈដែល ៩ ករណីកើតនៅខេត្តព្រះវិហារ និង ៤ ករណីកើតនៅខេត្តពោធិ៍សាត់ និងកំពង់ស្ពឺ។ ជាសរុប

គ្រួសារចំនួន ១៩,៧៤០ ឬ ប្រជាពលរដ្ឋចំនួន ៩២,៧៧៨ នាក់[២៦] បានរងផលប៉ះពាល់ពីវិវាទដីធ្លីទាក់ទិននឹងសម្បទានដីសេដ្ឋកិច្ច។

នៅខេត្ត និងក្រុងចំនួន ១០ ដូចជាខេត្តកំពង់ឆ្នាំង[២៧] កំពត កណ្ដាល កែប ប៉ៃលិន ព្រៃវែង សៀមរាប ស្ទឹងត្រែង តាកែវ និងរាជធានីភ្នំពេញ ពុំមានវិវាទដីធ្លីដែលបណ្ដាលមកពីសម្បទានដីសេដ្ឋកិច្ចទេក្នុងឆ្នាំ ២០១៣។




**រូបទី ៩៖ ចំនួនវិវាទដីធ្លីដែលទាក់ទិននឹងសម្បទានដីសេដ្ឋកិច្ច**

---

[២៦] តាមប្រព័ន្ធទិន្នន័យមានបញ្ជាក់ពីចំនួនប្រជាជនជាក់ស្ដែងដែលរងផលប៉ះពាល់ដោយវិវាទដីធ្លីដែលទាក់ទិននឹងសម្បទានដីសេដ្ឋកិច្ច។

[២៧] ខេត្តកំពង់ឆ្នាំងមានព្រំប្រទល់ជាមួយខេត្តពោធិ៍សាត់។ ត្រួតស៊ីគ្នាលើខេត្តទាំងពីរ គឺជាសម្បទានដីសេដ្ឋកិច្ចមួយដែលជាកម្មសិទ្ធិរបស់ក្រុមហ៊ុនភាភីម៉ិច (Pheapimex) ដែលបណ្ដាលឲ្យមានវិវាទដីធ្លីមួយ។ វិវាទដីធ្លីនេះដែលទាក់ទិននឹងសម្បទានដីសេដ្ឋកិច្ច ត្រូវបានដាក់បញ្ចូលក្នុងវិវាទដីធ្លីទាំង ៨ ទាក់ទិននឹងសម្បទានដីសេដ្ឋកិច្ចក្នុងខេត្តពោធិ៍សាត់។

# ៨. ការផ្លាស់កន្លែងដោយបង្ខំ

ករណីវិវាទដីធ្លីដែលបាននាំដល់ការផ្លាស់កន្លែងដោយបង្ខំ បានកើតឡើងក្នុងខេត្តជាច្រើន ហើយករណីសរុបចំនួន ៥០ ក្នុងចំណោម ករណីចំនួន ៣១១ ករណី ដែលកត់ត្រាដោយមជ្ឈមណ្ឌលស្រាវជ្រាវ និងព័ត៌មាន (RIC) តាំងពីឆ្នាំ ២០០៧ មានពាក់ព័ន្ធនឹងការផ្លាស់កន្លែងដោយបង្ខំ។

ក្នុងចំណោមករណីទាំងនេះ នៅខេត្តព្រះវិហារ មាន ៩ ករណី ដែលមានការផ្លាស់កន្លែងដោយបង្ខំ ខណៈដែល ៦ករណី កើតមាននៅរាជធានីភ្នំពេញ និងខេត្តព្រះសីហនុ។ ការផ្លាស់កន្លែងដោយបង្ខំបានប៉ះពាល់គ្រួសារចំនួន ១៤,២៤៧គ្រួសារ ឬប្រជាជនចំនួន ៦៦,៩៦០ នាក់[២៨]។ គួរកត់សម្គាល់ថាពុំមានករណីវិវាទដែលនាំឲ្យមានការផ្លាស់កន្លែងដោយបង្ខំនៅក្នុងខេត្តកំពង់ឆ្នាំង[២៩] កំពត ក្រចេះ និងព្រៃវែង ទេ។ នៅក្នុងឆ្នាំ ២០១៣ ការផ្លាស់កន្លែងដោយបង្ខំចំនួន ៤ ករណី បានកើតឡើងនៅខេត្តព្រះវិហារ និងបានប៉ះពាល់ប្រជាជនចំនួន ១,៧៦៨ នាក់[៣០]។

[២៨] តាមប្រព័ន្ធទិន្នន័យមានបញ្ជាក់ពីចំនួនប្រជាជនជាក់ស្តែងដែលរងផលប៉ះពាល់ដោយការផ្លាស់កន្លែងដោយបង្ខំ។

[២៩] ដូចលេខយោង ៨ ខាងលើ។

[៣០] សូមមើលឧបសម្ព័ន្ធទី ៤។




**រូបទី ១០៖ សម្បទានដីសេដ្ឋកិច្ចទាក់ទិននឹងការផ្លាស់កន្លែងដោយបង្ខំ ឆ្នាំ ២០០៧-២០១៣**

## ៩. សេចក្ដីសន្និដ្ឋាន

ផ្អែកលើការវិភាគស្ថិតិនៃទិន្នន័យវិវាទដីធ្លីរបស់មជ្ឈមណ្ឌលស្រាវជ្រាវ និងព័ត៌មាន (RIC) ខាងលើអ្នកសរសេរបានសង្កេតឃើញនិន្នាការដូចខាងក្រោម៖

- *ចំនួននៃវិវាទដីធ្លី៖* ចំនួននៃវិវាទដីធ្លីកើតថ្មីក្នុងឆ្នាំ ២០១៣ មានលក្ខណៈថយចុះធៀបទៅនឹងករណីដែលកត់ត្រាក្នុងរយៈពេលបីឆ្នាំ ចាប់ពីឆ្នាំ ២០១០ ដល់ឆ្នាំ ២០១២។

- *បណ្ដាខេត្តដែលរងផលប៉ះពាល់ពីវិវាទដីធ្លី៖* វិវាទបានកើតឡើងក្នុងទូទាំងប្រទេស។ ខេត្តដែលមានអត្រាវិវាទដីធ្លីខ្ពស់ជាងគេ គឺរាជធានីភ្នំពេញខណៈដែលខេត្តរតនគិរីស្ថិតក្នុងលំដាប់ទីពីរ។ ខេត្តផ្សេងទៀត ដូចជាខេត្តពោធិ៍សាត់ កំពង់ស្ពឺ កំពង់ចាម និងបន្ទាយមានជ័យ បានជួបប្រទះវិវាទដីធ្លីប្រហែល ២០ ករណី។

- *សម្បទានដីសេដ្ឋកិច្ច គឺជាមូលហេតុចម្បងមួយនៃវិវាទដីធ្លី៖* សម្បទានដីសេដ្ឋកិច្ច ជាប់ទាក់ទិននឹងវិវាទដីធ្លីចំនួន ៨០ និង គ្រួសារចំនួន ១៩,៧៤០ ឬ ប្រជាពលរដ្ឋចំនួន ៩២,៧៧៨ នាក់បានរងផលប៉ះពាល់។ ខេត្តរតនគិរី មណ្ឌលគិរី និង ព្រះវិហារ មានករណីវិវាទដែលជាប់ពាក់ព័ន្ធនឹងវិវាទខ្ពស់។

- *វិវាទដីធ្លីបាននាំទៅដល់ការផ្លាស់កន្លែងដោយបង្ខំ៖* ក្នុងឆ្នាំ ២០១៣ ករណីវិវាទដីធ្លីចំនួន ៤ បាននាំឲ្យមានការផ្លាស់កន្លែងដោយបង្ខំ ដែលករណីទាំងអស់សុទ្ធតែបានកើតឡើងក្នុងខេត្តព្រះវិហារ។

- *ចំនួនវិវាទដែលបានដោះស្រាយ៖* ពីឆ្នាំ ២០១០ ដល់ឆ្នាំ ២០១២ ចំនួនវិវាទដែលបានដោះស្រាយ បានកើនឡើង។ ចំនួននេះបានកើនឡើងពី ២០ ក្នុងឆ្នាំ ២០១០ ដល់ ៤០ ក្នុងឆ្នាំ ២០១១ និងបន្ទាប់មក ១០៨ ករណីក្នុងឆ្នាំ ២០១២។ ក្នុងឆ្នាំ ២០១៣ ចំនួនករណីបានដោះស្រាយបានថយចុះត្រឹម ៨១ ករណី។

# ១០. ឧបសម្ព័ន្ធ

ឧបសម្ព័ន្ធ កៈ ផែនទីគ្រួសារដែលរងផលប៉ះពាល់ពីករណីវិវាទដីធ្លីតាមខេត្ត ក្នុងឆ្នាំ ២០១៣
(សូមមើលផ្នែកភាសាអង់គ្លេស **Annex A** ទំព័រទី ២២)
ឧបសម្ព័ន្ធ ខៈ ប្រភេទដីដែលរងផលប៉ះពាល់ដោយវិវាទដីធ្លី តាមខេត្ត ក្នុងឆ្នាំ ២០១៣
(សូមមើលផ្នែកភាសាអង់គ្លេស **Annex B** ទំព័រទី ២២)
ឧបសម្ព័ន្ធ គៈ ផែនទីករណីវិវាទដីធ្លី តាមខេត្ត ក្នុងឆ្នាំ ២០១៣
(សូមមើលផ្នែកភាសាអង់គ្លេស **Annex C** ទំព័រទី ២២)
ឧបសម្ព័ន្ធ ទី ១ៈ ករណីវិវាទដីធ្លីថ្មី ចំនួន ២៨ ក្នុងឆ្នាំ ២០១៣
(សូមមើលផ្នែកភាសាអង់គ្លេស **Appendix 1** ទំព័រទី ២៥)
ឧបសម្ព័ន្ធ ទី ២ៈ ករណីវិវាទដែលបានដោះស្រាយក្នុងឆ្នាំ ២០១៣
(សូមមើលផ្នែកភាសាអង់គ្លេស **Appendix 2** ទំព័រទី ២៦)
ឧបសម្ព័ន្ធ ទី ៣ៈ វិវាទដីធ្លីក្នុងឆ្នាំ ២០១២
(សូមមើលផ្នែកភាសាអង់គ្លេស **Appendix 3** ទំព័រទី ៣០)
ឧបសម្ព័ន្ធ ទី ៤ៈ ការផ្លាស់កន្លែងដោយបង្ខំក្នុងឆ្នាំ ២០១៣
(សូមមើលផ្នែកភាសាអង់គ្លេស **Appendix 4** ទំព័រទី ៣១)